KhmerPost USA សារព័ត៌មាន ខ្មែរប៉ុស្ដិ៍ ស.រ.អា
Advertising: PA/NJ/NY: (267) 253-3947 MA/RI: (978) 656-8141

Vol 06 Issue 124 Feb. 22nd-March7th. 2013

មាតិការឿង | ទំព័រ


១-សម រង្ស៊ី ត្រូវត្រឡប់ទៅកម្ពុជា ដើម្បីឲ្យ.........................០២
២-ខ្មែរអ្នកជាតិនិយម.........................................................០៤
៣-អ្នកមាននិងអ្នកក្រនៅប្រទេសខ្មែរ....................................០៥
៤-The Cambodia daily..........................០៦និង០៩
៥- ក្តូបូលវីតណេសរាយការណ៍ពី....................................០៧
៦-សុខភាព និងម្ហូបអាហារយើងបរិភោគ.........................០៨


32 Wamesit St., Lowell, MA 01852. **Phone-Fax (978) 656 8141** www.khmerpost.us

## វិចារណកថា

## វេជ្ជកាលបន្ទាប់ពីសីហនុ

**ដោយៈ ពិន សំខុន**



●ផ្សែងបូជាព្រះបរមសពសម្តេចនរោត្តម សីហនុ អតីតព្រះមហាក្សត្រដ៏ខ្លាំងក្លាល្បីល្បាញបានហោះហើរអណ្តែតជាចុងក្រោយទៅលើវេហាដ៏ធំធេងភាពជ្រួលច្រាលនៃប្រជារាស្ត្រដែលស្តាយស្រណោះលំនឹងអតីតកាលកើតពីអំណាចសីហនុ ក៏បានស្ងប់ស្ងាត់ទៅវិញ នាសប្តាហ៍បន្ទាប់នេះ ។ រីឯអ្នកតាមដានព្រឹត្តិការណ៍នយោបាយក្នុងប្រទេសក្នុងតំបន់ និងទំនាក់ទំនងពិភពលោកមិនបានមើលឃើញថាជាភាពស្ងប់ ស្ងាត់មានដំណើរទៅរកសន្តិភាពនៅកម្ពុជានោះ



ទេ គេបានមើលឃើញថា "កម្ពុជាប្រៀបបានទៅនឹងភ្នំភ្លើងត្រៀមនឹងផ្ទុះសារជាថ្មី!"ហេតុអ្វី?

**១-គ្មានលំនឹងក្នុងតំបន់**

បុណ្យព្រះបរមសពសម្តេចសីហនុដ៏គគ្រឹកគគ្រេងបានបង្ហាញពីឥទ្ធិពលនៃប្រទេសចិនមកលើកម្ពុជាដោយការចំណាយថវិការដោយទំនាក់ទំនងកំពូលជាមួយផ្លូវទូតជាមួយមន្ត្រីជាន់ខ្ពស់ខ្មែរ ជាមួយព្រះរាជវង្ស ហើយជាចុងក្រោយជាន់ពេលគ្នា ចិនបានផ្តល់ជំនួយឧទ្ធម្ភាចក្រសង្គ្រាមច្រើនគ្រឿងដល់កម្ពុជា ។ ភាពរុងរឿងនៃកម្ពុជានាពេលនេះ ជាអំណាចរបស់អំណោយចិនដែលត្រៀមដាក់ **តទៅទំព័រទី១៦**

# វត្តខ្មែរឡូវែលឆ្លើយតបការចោទប្រកាន់ក្នុងកាសែត "ឡូសាន់"

**ពិន សំខុន**

វត្តខ្មែរឡូវែលដំណាងដោយព្រះអង្គចៅអធិការ សៅ ឃន មានព្រះទ័យខកចិត្តយ៉ាងខ្លាំង នាប៉ុន្មានថ្ងៃចុងក្រោយនេះ ដោយកាសែត "ឡូសាន់"បានចុះផ្សាយអត្ថបទមួយចោទប្រកាន់ថា មានអំពើពុករលួយទៅលើបច្ច័យដ៏ច្រើន **តទៅទំព័រទី ១២**



គម្រោងសង់ព្រះវិហារលើដីថ្មីនៃវត្តខ្មែរឡូវែល


I DO TAXES

ខ្ញុំទទួលធ្វើតាក់ជូនលោកអ្នក
ហើយទទួលប្រាក់ធានឆាប់
ការិយាល័យមេធាវី ថំមាស ស្តាលីយ៉ាណូស



Law Office of Thomas Stylianos
287 Appleton Street Lowell MA 01852
(978) 459-5000





សុខភាពល្អប្រសើរក្នុងដៃលោកអ្នក

បើលោកអ្នកមានជំងឺ ឈឺហើមជើងដៃពិបាកធ្វើចលនា -ឈឺនោមច្រើន -ដេកស្រម៉ុកខ្លាំង -មានស្លេស្មច្រើនក្នុងឈាម -ឡើងទម្ងន់ធាត់ -ស្បែកឡើងកន្ទួល លោកអ្នកត្រូវចាំថា មានឱសថសក្តិសិទ្ធមានលក្ខណៈជាប្រភេទចំណី អាចជួយឱ្យសះស្បើយបានយ៉ាងឆាប់រហ័ស ។ ឱសថធម្មជាតិ ជាប្រេងចម្រាញ់ចេញពីពន្លកគ្រាប់ស្រូវមានការត្រួតពិនិត្យដោយវេជ្ជបណ្ឌិតត្រឹមត្រូវ អាចប្រើដោយមិនប្រឆាំងនឹងថ្នាំពេទ្យ ដែលប្រើប្រាស់រាល់ថ្ងៃទេ ។

លោក វិចិត្រ ភូស៊ីរុំឌ ៦២ឆ្នាំ មុនប្រើ"អេមស្តា" គាត់ឈឺទឹក នោមផ្អែម ឈឺបេះដូង លើសឈាម -"អាលើជី"-ឈឺសន្លាក់ ដៃជើង ឈឺក្រពះ...។ល។

**បន្ទាប់ពីបានប្រើ"អេមស្តា"**

លេប៩គ្រាប់ក្នុង១ថ្ងៃ-បីថ្ងៃក្រោយមក អន់ឈឺសន្លាក់ដៃជើង -១ខែក្រោយអាចរត់ឡើងជណ្តើរបាន-បីខែក្រោយទៀតសរសៃឈាម២លែងស្ទះ-ឥឡូវនេះអាចរត់បាន១០គីឡូម៉ែត្រ-ធ្វើតេស្តឈាមមានភាពហ្វឹងធំល្អឡើងវិញ។





**ចង់ដឹងបន្ថែមលេខទូរស័ព្ទលេខ**
-ហ្វូឡាខាងត្បូង ២១៥ ២៣៧ ៥៧០៩ សាមន់ថា
-ហ្វូឡាខាងជើង ២១៥ ៦៦៧ ៨៤៣១ រ៉េដ៉រ

# សម រង្ស៊ី ត្រូវត្រឡប់នៅកម្ពុជា
## ដើម្បីឱ្យ"ការបោះឆ្នោតខ្មែរយកជាការបាន"

អនុរដ្ឋលេខាធិការអាមេរិកាំង ម៉ាយកិល ប៉ូស្នឺ Michael Posners ផ្នែកខាងប្រជាធិបតេយ្យ និងសិទ្ធិមនុស្សបាននិយាយកាលពីថ្ងៃអង្គារ៍នេះនៅភ្នំពេញថា **"ការបោះឆ្នោតយកជាការបាន គឺអាស្រ័យលើលទ្ធភាពដែលបក្សប្រឆាំងអាចចូលរួមបានពេញលេញ និងស្មើភាពគ្នា"**។ ក្នុងពេលនេះលោក សម រង្ស៊ី បាន និរទ្ទេសខ្លួនដើម្បីគេចខ្លួនពីការចាប់ដាក់ពន្ធនាគារ១១ឆ្នាំ ពីបទក្លែងបន្លំគំនូសផែនទីរវាងខ្មែរ-វៀតណាមពីបទញុះញង់ឱ្យមានការប្រកាន់ពូជសាសន៍ និងប្រមាថដល់រដ្ឋមន្ត្រីក្រសួងការបរទេសខ្មែរ ។លោកជាសមាជិកសភាជាប់ឆ្នោតជាសកលតែបានត្រូវដកសិទ្ធិដោយសភាជាតិ ដែលគណបក្ស ប្រជាជនមានសម្លេងលើស២/៣ ។ គណបក្សរបស់លោកបានចងសម្ព័ន្ធជាមួយបក្សប្រឆាំងមួយទៀត គឺគណបក្សសិទ្ធិមនុស្ស ដើម្បីទៅប្រកួតយកការទុកចិត្តពីពលរដ្ឋខែកក្កដាឆ្នាំ២០១៣នេះ តែគណកម្មការរៀបចំការបោះឆ្នោតប្រកាសថា "លោក សម រង្ស៊ី ជាទណ្ឌិតពុំមានសិទ្ធិឈរឈ្មោះ ឬចូលរួមការបោះឆ្នោតទេ" ។

លោកអនុរដ្ឋលេខាធិការអាមេរិកាំងបាន បន្តថា



"រដ្ឋាភិបាលត្រូវចាត់វិធានការណ៍ឱ្យបានច្បាស់លាស់ និងថ្លឹងថ្លែង ដើម្បីបង្កើតលក្ខខណ្ឌស្មើភាពសម្រាប់ទាំងអស់គ្នា និងសម្រាប់លោក សម រង្ស៊ី ដែរ" ហើយបន្ថែមថា "វិធីបោះឆ្នោតនឹងបង្ហាញពីបំណងរបស់រដ្ឋាភិបាលដែលថា លើកតម្កើងប្រជាធិបតេយ្យ និងពហុបក្ស ឬក៏អត់" ។

**តទៅទំព័រទី ០៦**

# បុណ្យផ្កាប្រាក់សាមគ្គី

**គណៈកម្មាធិការរៀបចំបុណ្យចូលឆ្នាំខ្មែរ**រួមជាមួយពុទ្ធបរិស័ទដែលមានរាយនាមដូចខាងក្រោម បានមូលមតិគ្នាជាឯកច្ឆ័ន្ទផ្តួចផ្តើមធ្វើ**បុណ្យផ្កាប្រាក់សាមគ្គី**មួយ នៅ**ថ្ងៃសៅរ៍ ទី២៣ ខែមិនា ឆ្នាំ២០១៣** ដើម្បីប្រមូលបច្ច័យយកទៅរៀបចំពិធី**បុណ្យចូលឆ្នាំថ្មីប្រពៃណីយខ្មែរ**ជាសាធារណៈ នៅថ្ងៃសៅរ៍ ទី១៣ ខែមេសា ឆ្នាំ២០១៣ ខាងមុខនេះ។

**គណៈកម្មាធិការរៀបចំបុណ្យចូលឆ្នាំខ្មែរ** មានបំណងចង់រក្សាទំនៀមទំលាប់ និងប្រពៃណីយជាតិខ្មែរ ជាពិសេសដើម្បីផ្សព្វផ្សាយនូវល្បែងប្រជាប្រិយខ្មែរដែលជាកេរមរតកដ៏ថ្លៃថ្លាទាំងនោះ ដល់កុលបុត្រ កុលធិតាខ្មែរជំនាន់ក្រោយនៅសហរដ្ឋអាមេរិកឱ្យបានស្គាល់និងចងចាំគ្រប់ៗគ្នា ។ អាស្រ័យហេតុនេះ ខ្ញុំព្រះករុណាយើងខ្ញុំទាំងអស់គ្នា សូមនិមន្តនិងអញ្ជើញព្រះតេជគុណគ្រប់ព្រះអង្គ លោកយាយ លោកតា លោក លោកស្រី យុវជន យុវតី និងជនរួមជាតិខ្មែរនៅសហរដ្ឋអាមេរិក ចូលរួមក្នុងពិធី**បុណ្យផ្កាប្រាក់សាមគ្គី**នេះ ឱ្យបានច្រើនកុះករ ជួយចាប់កុសលនិងអនុមោទនាទទួលយកនូវមគ្គផលទៅតាមកំលាំងសទ្ធាជ្រះថ្លារៀងៗខ្លួន ។

## កម្មវិធីបុណ្យ

**ថ្ងៃ១២ កើត ខែផល្គុន ឆ្នាំរោង ចត្វាស័ក ពុទ្ធសករាជ២៥៥៦ ត្រូវនឹង**

**ថ្ងៃសៅរ៍ ទី២៣ ខែមិនា ឆ្នាំ២០១៣** (Saturday, March 23, 2013)

- **ម៉ោង៩:០០នាទី** : ជួបជុំពុទ្ធបរិស័ទជិតឆ្ងាយ នមស្សការ សមាទានសីល
- **ម៉ោង១០:៣០នាទី**: វេរភត្តហា ដារបង្សុកូលឧទ្ទិសកុសល.ប្រគេនចង្ហាន់ព្រះសង្ឃ
- **ម៉ោង១២:០០នាទី**: ទទួលទានអាហារជាកិច្ចបង្ហើយបុណ្យ

**ទីកន្លែង:** **វត្តពន្លឺពុទ្ធចក្ក** (GLORY BUDDHIST TEMPLE)

24 Cambridge Street, Lowell, MA 01851

**ពត៌មានបន្ថែមសូមទាក់ទង: លោក វាសនា នួន** Tel: (978) 835 4996 **លោក សេងលី គង់** Tel: (978) 364 1911, **លោក ឱក តុលាយុត្តិ** Tel: (978) 996 6758 **លោក អ៊ូ សុវណ្ណ** Tel: (978) 735 4539

**សូមអរព្រះគុណ និងសូមអរគុណ ។**


"នាងប្រាប់ខ្ញុំគ្រប់យ៉ាង
ខ្ញុំសប្បាយចិត្តខ្លាំងណាស់។
នាងពេញចិត្តនៅផ្ទះជាមួយយើង។"



CAREGIVER™ HOMES

Caregiver Homes™ ជួយចាស់ជរា និងជនពិការឱ្យរីករាយជាមួយ នឹងគុណភាពខ្ពស់នៃជីវិតនៅផ្ទះ

- បង់ប្រាក់ & បង្រៀនបណ្តុះបណ្តាល អ្នកថែទាំពេញពេលដែលរស់នៅជាមួយ
- ផ្តល់ជំនួយ ប្រកបដោយវិជ្ជាជីវៈ ពីគិលានុបដ្ឋាយិកា និង អ្នកថែទាំ ដែលចេះយកចិត្តទុកដាក់
- ជួយអ្នកស្វែងរក & ទទួលបានគ្រប់សេវាដែលចាំបាច់

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនង 866.797.2333 ឬចូលមកគេហ៍ទំព័ររបស់យើង។
WWW.CAREGIVERHOMES.COM



# បុណ្យទក្ខិណានុប្បទានរំលឹកខួប ៦ ឆ្នាំ

## សម្តេចព្រះមហាឃោសានន្ទ

ព្រះសង្ឃាធិបតី **សៅ ឃន** ធម្មថេរោ ប្រធានសហគមន៍ព្រះសង្ឃខ្មែរសហរដ្ឋអាមេរិក ព្រះសង្ឃ និងពុទ្ធបរិស័ទ នៅទីក្រុងឡូវែល រដ្ឋម៉ាស្សាឈូសេត ក៏ដូចជាទីក្រុងនិងរដ្ឋផ្សេងៗទៀត មានកតញ្ញូកតវេទិតាធម៌ និងសទ្ធាជ្រះថ្លា បានរួបរួមគ្នាធ្វើបុណ្យទក្ខិណានុប្បទាន ឧទ្ទិសមហាកុសលថ្វាយព្រះវិញ្ញាណក្ខ័ន្ធ **សម្តេចព្រះមហាឃោសានន្ទ** ដែលបានចូលទិវង្គតទៅគម្រប់ប្រាំមួយឆ្នាំ ។

អាស្រ័យហេតុនេះ ខ្ញុំព្រះករុណាអាត្មាភាព យើងខ្ញុំ សូមអារាធនានិមន្តព្រះថេរានុត្ថេរៈគ្រប់អង្គ និងអញ្ជើញអស់លោក លោកស្រី ញាតិមិត្រពុទ្ធបរិស័ទ និងសប្បុរសជន ជិតឆ្ងាយចូលរួមក្នុងពិធីបុណ្យទក្ខិណានុប្បទាននេះ និងអនុមោទនាយកកុសល តាមសទ្ធាជ្រះថ្លាកុំបីអាក់ខាន ។

### កាលបរិច្ឆេទ និង ទីកន្លែងបុណ្យ

មណ្ឌលសហគមន៍ព្រះសង្ឃខ្មែរ (វត្តខ្មែរឡូវែល)

Lowell Elks Lodge
40 Old Ferry Rd. Lowell, MA 01854
Tel. (978) 251-2587 or (978) 501-0106

ថ្ងៃអាទិត្យ ទី១៧ ខែមីនា ត្រូវនឹងថ្ងៃ ៦ កើត ខែផល្គុន ឆ្នាំរោង ចត្វាស័ក
ព.ស. ២៥៥៦ គ.ស. ២០១៣

**Sunday, March 17, 2013**

### កម្មវិធីបុណ្យ

9:30 – 11:00 ជួបជុំពុទ្ធបរិស័ទជិតឆ្ងាយ នមស្សការព្រះរតនត្រ័យ សមាទានសីល ព្រះសង្ឃចំរើនព្រះបរិត្ត រាប់បាត្រ វេរចង្ហាន់ ដារបង្សុកូល

11:00 – 12.00 និមន្តព្រះធម្មកថិកសំដែងធម៌ទេសនា បន្ទាប់មកឧទ្ទិសកុសលថ្វាយ ព្រះវិញ្ញាណក្ខ័ន្ធ **សម្តេចព្រះមហាឃោសានន្ទ** និងបុព្វការីជន ញាតិកជនជាកិច្ចបញ្ចប់បុណ្យ ។

# ខ្មែរអ្នកជាតិនិយម

តពីលេខមុន

របស់កងទ័ពយួនបានយូរអង្វែងឡើយ ។

ក្នុងស្ថានភាពនៃការឡោមព័ទ្ធរបស់កងទ័ពយួននេះក៏បានប្រមូលផ្តុំគ្នានៅតែក្នុងបន្ទាយធ្វើការទប់ទល់ និងការវាយប្រហាររង់ចាំជំនួយមកដល់ ។ មួយឆ្នាំក្រោយមក ទើបកងទ័ពជំនួយបារាំងដែលចុះពីប្រទេសចិនមកដល់ ហើយមិនត្រឹមតែវាយបំបែកការឡោមព័ទ្ធនៃកងទ័ពយួនប៉ុណ្ណោះទេ គឺថែមទាំងវាយយកបានខេត្តចំនួន៣ នៅទិសខាងជើងក្រុងព្រៃនគរទៀតផង ។

នៅថ្ងៃទី ៥ កក្កដា ១៨៦២ អធិរាជ ទឺឌឹក ដែលមានការមមាញឹកក្នុងការបង្ក្រាបអំពើបះបោរនៅតុងកឹងនោះ ក៏បានចុះហត្ថលេខាលើសន្ធិសញ្ញាមួយជាមួយឧត្តមនាវី ប៉ុល បូណ្ណា (Paul Bonna ) ដែលនៅក្នុងសន្ធិសញ្ញានោះចែងថា យួនអនុញ្ញាតឱ្យមានសេរីភាពក្នុងការកាន់សាសនា កាតូលិក ព្រមទាំងត្រូវប្រគល់ខេត្តទាំង៣ដែលបារាំងវាយយកបាននោះទៅឱ្យបារាំង គឺខេត្តបៀងហ្វា,យ៉ាឌិន និងវិញឡើង ព្រមទាំងកោះត្រឡាចដែលគ្រានោះកម្ពុជាក្រោមបានត្រូវស្តេចខ្មែរបោះបង់ចោលរួចទៅហើយ ក៏ប៉ុន្តែបណ្តាជនខ្មែរនៅតែធ្វើការប្រឆាំង និងការត្រួតត្រារបស់យួនចាដរាបរៀងមក ។



និពន្ធដោយ ឡឹក សំអឿន ហៅ "ផ្កាយព្រឹក"

**ចប់វគ្គទី១**

**វគ្គទី២**

បារាំងវាយយកបានកម្ពុជាក្រោមពុំទាន់បានពាក់កណ្តាលផង ក៏ស្រាប់តែចោលភ្នែកសម្លឹងចង់ត្របាក់យកកម្ពុជាទាំងមូលទៀត ព្រោះក្នុងរាជ្យព្រះបាទអង្គឌួង ទ្រង់បានធ្វើការទាក់ទងដ៏សម្ងាត់មួយជាមួយបារាំងតាមរយៈ ម៉ុងសៃញ៉េរ មិស (Monseignur Mich) ដែលជាមេគណបារាំងប្រចាំកម្ពុជាក្រោម ដើម្បីឱ្យបារាំងជួយការពារប្រទេសកម្ពុជា កុំឱ្យសៀមឈ្លានពាន ។ ប៉ុន្តែពញារាជាសៀមដែលជាដំណាងស្តេចសៀមបានដឹងអាថិកំបាំងនេះជាមុន ។ ឯកសារខ្លះនិយាយថា ព្រះអង្គឌួង បានសរសេរទៅណាប៉ូឡេអុងក្នុងគោលបំណងចង់ចងសម្ព័ន្ធមេត្រី ដើម្បីការពារទឹកដីខ្មែរ សុំឱ្យបារាំងគោរពបូរណភាពទឹកដីខ្មែរ ហើយពុំបានសុំឱ្យបារាំងធ្វើអាណាព្យាបាលមកលើខ្មែរទេ ។ ប៉ុន្តែព្រះអង្គឌួងបានសោយទិវង្គត់ទៅនៅឆ្នាំ១៨៦០ ក្នុងក្តីអាថិកំបាំងជាទីបំផុត ។

នៅខែសីហា ១៨៦២ ក្នុងពេលដែលព្រះបាទនរោត្តម (រាជបុត្រទី១ របស់អង្គឌួង) វិលត្រឡប់ពីប្រទេសសៀមមកវិញ ដោយអន្តរាគមនៃម៉ុងសៃញ៉េរមិស និងតាមរយៈកុងស៊ុលបារាំងក្រុងបាងកក ឧត្តមនាវីបារាំងឈ្មោះ ប៉ូល បូណ្ណា (Paul Bonna) បានមកធ្វើទស្សនកិច្ចជាផ្លូវការនៅក្រុងឧត្តុង្គ ដែលកាលនោះជារាជធានីនៃប្រទេសខ្មែរដោយមានម៉ុងសៃញ៉េរមិសជូនដំណើរផង ។ បារាំងចង់ស្ទង់ស្ទាបមើលថា កម្ពុជាមានបំណងចង់ទទួលយកបារាំងជាអាណាព្យាបាក ឬទេ ព្រោះបើយកកម្ពុជាក្រោមបានតទៅមុខ គេក៏ត្រូវយកកម្ពុជា-លាវដែរ ព្រោះប្រទេសលាវមិនត្រឹមតែមានផ្លូវទឹកមួយតាមដងទន្លេមេគង្គទៅកាន់ប្រទេសចិនភាគខាងត្បូងដើម្បីធ្វើជំនួញតែប៉ុណ្ណោះទេ គឺថែមទាំងជាព្រំដែនធម្មជាតិបាំងអាណានិគមបារាំង និងអាណានិគមអង់គ្លេសទៀតផង ។ ទស្សនិកជននៃការស្ទង់ស្ទាបនេះ បានបង្ហាញយ៉ាងច្បាស់ថា គង់នឹងសម្រេចដូចបំណង ។

នៅថ្ងៃទី១០ សីហា ១៨៦៣ ឧត្តមនាវី ដឺឡាហ្គ្រង់ឌីយែរ (De Lagrandire) ជាទេសាភិបាល ទី១ប្រចាំឥណ្ឌូចិន ដោយមានម៉ុងសៃញ៉េរមិស ជូនដំណើរផង បានមកដល់ឧត្តុង្គជួបនឹងព្រះបាទនរោត្តម ហើយក៏បានបញ្ចុះបញ្ចូលទ្រង់ឱ្យចុះហត្ថលេខាលើសន្ធិសញ្ញាមួយទទួលយកបារាំងជាអាណាព្យាបាលខ្មែរ ។ នៅពេលនេះ ពញារាជាសៀមបានធ្វើដំណើរទៅបាងកក ។ សន្ធិសញ្ញានេះបានត្រូវបារាំង ណាប៉ូឡេអុងទី៣ ចុះហត្ថលេខានៅពេលក្រោយ ។ តមកនរោត្តមក៏ត្រូវបានអភិសេកទទួលមកុដរាជ្យនៅថ្ងៃទី៣ មិថុនា ១៨៦៤ ក្រោមអធិបតីនៃអ្នកតំណាងរាស្ត្របារាំងម្នាក់ឈ្មោះ ឌូដា ដឺឡាហ្គ្រេ (Doudar de Lagree) និងពញារាជាជាតំណាងសៀមព្រមទាំងបានបង្កើតទង់ជាតិខ្មែរដែលមានពណ៌ខៀវព័ទ្ធជុំវិញពណ៌ក្រហម និងមានរូបប្រាសាទអង្គរវត្តពណ៌សនៅចំកណ្តាល មានភ្លេងជាតិ បទនគររាជ្យទំនុកច្រៀងតែងឡើងដោយវរសេនីយ៍ត្រីពេទ្យបារាំងម្នាក់ ។

ដើម្បីកុំឱ្យសៀមឆាឆៅសន្ធិសញ្ញានេះ បារាំងបានសន្យាយ៉ាងសម្ងាត់ជាមួយសៀមថា ខ្លួននឹងប្រគល់ដែនដីខ្មែរមួយចំនួនទៅឱ្យសៀមនៅពេលខាងក្រោយ ។

ក្នុងអំឡុង២ឆ្នាំដំបូងនៃរាជ្យព្រះបាទនរោត្តម ព្រះអង្គបានប្រឈមមុខទប់ទល់នឹងចលនាបះបោរ ២ក្រុម មានពោរកំបោរជាមេដឹកនាំ ។ ចលនាទី១ ត្រូវបានបារាំងបង្ក្រាបបានយ៉ាងឆាប់រហ័សដោយពួកគេបានសម្លាប់អាចារ្យស្វានៅឆ្នាំ១៨៦៦ ។ ឯចលនាទី២ ដែលមេដឹកនាំបានប្រកាសថា **តទៅលេខក្រោយ**






# អ្នកក្រ និងអ្នកមាននៅប្រទេសខ្មែរ ភាគទី៥



គីម សុស មន្ត្រីចូលនិវត្ត ក្រសួងការបរទេស សហរដ្ឋអាមេរិក

**តពីលេខមុន**

ថ្ងៃមុននៅចុងក្រោយបង្អស់នៃភាគទី៤និយាយអំពីរឿងអ្នកក្រអ្នកមាននេះ ខ្ញុំបានជម្រាបថា ខ្ញុំនឹងជម្រាបអំពី "អ្នកមានចង់មានពេកភ្លេចគិតដល់អ្នកក្រ"។

រឿងថាភ្លេចគិតនេះ ក៏ថាបាន។ ព្រោះថានេះជារឿងទូទៅរបស់មនុស្ស ។ កាលណាយើងស៊ប់ប្អងប់តែនឹងអ្វីមួយហើយ យើងច្រើនតែភ្លេចអ្វីឯទៀត។ ប៉ុន្តែតាមបទពិសោធរបស់ខ្ញុំរឿងថា"អ្នកមានចង់មានពេកភ្លេចគិតដល់អ្នកក្រ" នេះមានករណីតិចណាស់បើមានមែន។ តែផ្ទុយទៅវិញ ករណីភាគច្រើន ច្រើនតែមិនគិតដល់អ្នកក្រព្រោះចង់មានពេកចង់មានឱ្យបានឆាប់រហ័សគ្មានគិតដល់អ្នកណាក្រៅពីខ្លួនឯងទេ។

ហើយម្យ៉ាងទៀត រឿង "ចង់មានពេកចង់មានឱ្យបានឆាប់រហ័ស" តាមការសង្កេតរបស់ខ្ញុំជាបញ្ហាទូទៅក្នុងជំនួញទូទៅនៅពិភពលោកដូចជានៅសហរដ្ឋអាមេរិកជាដើម។ នៅសហរដ្ឋអាមេរិកប្រមាណ៥០០នាក់នៃពលរដ្ឋប្រមាណ៣១៤លាននាក់ជាអ្នកមានអណ្តែតដាច់ផុតពីគេដែលជាភាសាអង្លេស Super- Rich។ ហើយចំពោះមនុស្សមួយភាគតូចមួយនេះ គឺជាង១ភាគរយនៃពលរដ្ឋរួមនឹងចំនួនអ្នកមានមធ្យមនៃជនជាតិអាមេរិកាំងឯទៀតផង រដ្ឋាភិបាលសហរដ្ឋអាមេរិកកំពុងរិះរកមធ្យោបាយធ្វើយ៉ាងដូចម្តេចឱ្យធនធាន គឺលុយនៃក្រុមអ្នកមាននេះចេញទៅជួយអ្នកឯទៀតដោយបង្កើតការងារឱ្យអ្នកឯទៀតនោះធ្វើ និងជួយរដ្ឋាភិបាលដោយបង់ពន្ធឱ្យបានច្រើនជាងចំនួនដែលត្រូវបង់ឥឡូវនេះ ដើម្បីបង្កើនប្រាក់ចំណូលទៅថវិការជាតិ។ ត្រង់នេះយើងអាចនិយាយបានថា រដ្ឋាភិបាលអាមេរិកាំងមិនចាំអ្នកមានគិតទៅដល់អ្នកក្រទេ ឬក៏យើងអាចនិយាយបានថា រដ្ឋាភិបាលអាមេរិកាំងមិនសង្ឃឹមថា អ្នកមានអាមេរិកាំងភាគច្រើនគិតដល់អ្នកក្រដែរ ។ ព្រោះថាអ្នកមានកាន់តែមានច្រើនឡើងៗហើយលឿនឡើងៗ។ ហើយចំនួនអ្នកអត់ការធ្វើជួនកាលឡើងជួនកាលចុះ។ ដូច្នេះរដ្ឋាភិបាលត្រូវចាត់វិធាការ ដើម្បីធានាស្ថេរភាព និងភាពចម្រុងចម្រើនរបស់ស្រុក។




ឈ្មោះ សូភី លើរថយន្ត...

ចំពោះស្រុកខ្មែរវិញ អ្នកមានមិនត្រូវយករឿងភ្លេកគិតដល់អ្នកអត់ការធ្វើនិងអ្នកក្រមកជជែកដេញដោលឱ្យខាតពេលទេ។ អ្នកមានត្រូវចាប់ផ្តើមរកមធ្យោបាយបង្កើតការងារដើម្បីកាត់បន្ថយចំនួនអ្នកអត់ការធ្វើនិងចំនួនអ្នកក្រដែលនៅក្នុងចំនួននេះមានប្រមាណ៨០ភាគរយពឹងផ្អែករបរកសិកម្មឱ្យបានឆាប់រហ័ស ។ អ្នកមានអាចថាបានថា រឿងកាត់បន្ថយនេះជាភារកិច្ចរបស់រាជរដ្ឋាភិបាល ។ ប៉ុន្តែតើអ្នកមានអាចធ្វើខ្លួនឯងដោយមិនចាំបាច់មានការគាបសង្កត់ពីណាមួយមកបានទេ ?

អ្នកមាននៅស្រុកខ្មែរ ជាពិសេសអ្នកមានខ្មែរ ត្រូវសួរខ្លួនឯងមើលថាតើសព្វថ្ងៃនេះព្រួយបារម្ភអ្វីឬទេ នៅវេលានេះដែលមានចំនួនអ្នកអត់ការធ្វើ និងអ្នកក្រកាន់តែច្រើនឡើងច្រើនឡើងកាន់តែក្រទៅក្រទៅហើយចំនួនអ្នកមានស្មើរតែនៅដដែលកាន់តែមានឡើងមានឡើង? អ្នកមានខ្មែរមើលឃើញទេថាផ្ទះខ្លួនធំដាច់គេមានរបងខ្ពស់មានអ្នកយាមរាល់ពេលវេលា? **តទៅទំព័រទី ១៥**

KHMER POST USA, LLC
East Coast Publication

**Pin Samkhon,**
*Publisher & Editor-in-Chief*
Email: pinsamkhon@gmail.com
*Staff Writers:* **Loeum Im**

*Contributed Writers:*
**Mam Yin, Kim Phien**
*Layout*
**Heng ChhunLeng**
*Advertising Department*
**Soben Pin**
KhmerPostUSA@gmail.com
**267-253-3947**

**Sam Khoeun**
*Sales Consultant*
**(781) 244-0522**

KhmerPost USA, LLC
438 LINDLEY AVE.
Philadelphia, PA 19120

# សាខាគណបក្ស សម រង្ស៊ី និងសិទ្ធិ មនុស្សនៅហ្វីឡាដែលហ្វៀ រួមគ្នាស្វែង រកថវិកាជួយបក្សសង្គ្រោះជាតិដែល ទើបប្រសូត្រថ្មី

**ដោយ : អ៊ឹម លឿម**



**អ៊ឹម លឿម**

សាខាគណបក្សសិទ្ធិ មនុស្ស និងសាខាគណបក្ស សម រង្ស៊ី ប្រចាំរដ្ឋផែនស៊ីវេនៀ (PA) ដែលកំពុងស្ថិតក្រោមផ្លាក "ចលនាប្រជាធិបតេយ្យសង្គ្រោះជាតិ" កាលពីថ្ងៃសៅរ៍ ទី៩ ខែកុម្ភៈ កន្លងមកនេះ បានរួមគ្នាប្រារព្ធធ្វើពិធីរាត្រីសមោសមួយដើម្បីអបអរទិវារនៃក្តីស្រលាញ់នៅភោជនីយដ្ឋាន Golden Palace ស្ថិតនៅតំបន់ហ្វីឡាដែលហ្វៀខាងត្បូងដោយមានការចូលរួមពីសំណាក់ភ្ញៀវជាតិ,អន្តរជាតិក្រុមពាណិជ្ជករក្នុងតំបន់ និងក្រុមអ្នកនយោបាយនានា ព្រមទាំងអង្គការសង្គមស៊ីវិលជាច្រើនក្រុម ។

នេះអាចចាត់ទុកបានថា ជាជោគជ័យមួយដ៏ធំសម្រាប់សាខាគណបក្សនយោបាយទាំងពីរដែលបានសហការណ៍ក្នុងការស្វែងរកថវិការសម្រាប់ដាក់ក្នុងហិប"មូលនិធិសង្គ្រោះជាតិ" ប្រយោជន៏សម្រាប់ផ្គត់ផ្គង់ដល់ស្នូលគណបក្ស "សង្គ្រោះជាតិ"ដែល ទើបបានប្រសូត្រចេញពីគណបក្សប្រឆាំងពីរដែលតែងតែអះអាងថាជាបក្សប្រជាធិបតេយ្យ គឺគណបក្ស សម រង្ស៊ី និងគណបក្សសិទ្ធិមនុស្ស ។

តាមការឱ្យដឹងពីលោក វ៉ា សាម៉ុន ប្រធានចលនាប្រជាធិបតេយ្យសង្គ្រោះជាតិប្រចាំតំបន់ហ្វីឡាដែលហ្វៀបានឱ្យ "ខ្មែរផុស"ដឹងថា ប្រាក់ឧបត្ថម្ភដែលប្រមូលបាននារាត្រីនោះមានចំនួនជាង១ម៉ឺនដុល្លារ ប៉ុន្តែទូទាត់លើខ្ទង់ចំណាយផ្សេងៗនៅសល់តែជិត១ម៉ឺនដុល្លារប៉ុណ្ណោះ ។ លោក សាម៉ុន បានឱ្យដឹងទៀតថា ទោះជាយ៉ាងណាក៏ដោយ



ចំនួនទឹកប្រាក់នោះនៅពុំទាន់គ្រប់គ្រាន់លើទិដ្ឋភាពជាក់ស្តែងចំពោះតម្រូវការបក្សនៅប្រទេសកម្ពុជាឡើយ ហើយសាខាបក្សទាំងពីរ (សម រង្ស៊ី និងសិទ្ធិមនុស្ស) ដែលកំពុងតែស្ថិតនៅក្រោមផ្លាក "ចលនាប្រជាធិបតេយ្យសង្គ្រោះជាតិ"នៅឡើយ និងធ្វើពិធីរាត្រីសមោសបក្សម្តងទៀត នៅខែមេសា ខាងមុខនេះដោយមានការអញ្ជើញចូលរួមពីលោក សម រង្ស៊ី និងលោក កឹម សុខា ។

យោងតាមប្រភពធ្លាយចេញពីថ្នាក់ដឹកនាំប្រចាំទ្វីបអាមេរិកខាងជើង(អាមេរិក-កាណាដា) ហាក់នៅជាប់គាំងនៅឡើយ ទោះបីជាមានការជជែកពិភាក្សាគ្នាជារឿយៗជុំវិញបញ្ហានេះក៏ដោយចុះ ។ បញ្ហាចម្បងដែលរាំងស្ទះដល់ដំណើរការរៀបចំរចនាសម្ព័ន្ធសម្រាប់សាខាបក្សសង្គ្រោះ



ទិដ្ឋភាពរាត្រីពិធីជប់លៀងប្រមូលថវិកា

សាខាគណបក្សសិទ្ធិមនុស្សប្រចាំរដ្ឋផែនស៊ីវេនៀបានបង្ហើបឱ្យដឹងថា រហូតមកដល់ពេលនេះ ចលនាសម្ព័ន្ធរបស់សាខាគណបក្សសង្គ្រោះជាតិប្រចាំទ្វីបអាមេរិកខាងជើងនេះ គឺការមិនឯកភាពគ្នាលើតំណែង និងតួនាទីក្នុងជួរបក្ស ៕

ឌឹ ខេមបូឌា ដេលី The Cambodia Daily

ដំណឹងប្រែសម្រួលពីកាសារអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ខេមបូឌា ដេលី ច្បាប់ចេញផ្សាយថ្ងៃ ច័ន្ទ ទី១៨ ខែ កុម្ភៈ ឆ្នាំ២០១៣

# ប្រជាពលរដ្ឋប្រណាំងរទេះគោប្រចាំឆ្នាំ ដើម្បីប្រារព្ធពិធីបញ្ចប់ដូវច្រូត កាត់នៅខេត្តកំពង់ស្ពឺ

**ម៉ិច ដារ៉ា**

កាលពីម្សិលមិញ ប្រជាពលរដ្ឋប្រហែល ២០០នាក់បានចូលរួមទស្សនាការប្រណាំងរទេះគោប្រចាំឆ្នាំ ដើម្បីប្រារព្ធពិធីបញ្ចប់រដូវច្រូតកាត់នៅខេត្តកំពង់ស្ពឺ ។ ផលនោះបានបញ្ចប់នៅចុងខែមករា ។

លោក មាស ផាត បានមានប្រសាសន៍បន្ថែមទៀតថា "យើងបានរៀបចំការប្រណាំងរទេះគោបន្ទាប់ពីរដូវច្រូតកាត់នីមួយជារៀងរាល់ឆ្នាំ ហើយយើងព្យាយាមរក្សាប្រពៃណីនេះសម្រាប់ក្មេងៗ



លោក មាស ផាត អ្នករៀបចំម្នាក់ក្នុងចំណោមអ្នករៀបចំកម្មវិធីប្រណាំងរទេះគោនេះមានប្រសាសន៍ថា នេះជាទំនៀមទំលាប់ប្រពៃណីក្នុងការប្រណាំងរទេះគោនេះ បន្ទាប់ពីការប្រមូលជំនាន់ក្រោយ ដើម្បីឱ្យពួកគេអាចយល់ដឹងអំពីប្រពៃណីរបស់យើង" លោកបានបន្ថែមទៀតថា ដោយមានរទេះគោចំនួន៣០គ្រឿង ព្រមទាំងអ្នកបររទេះដ៏ក្លាហានផងដែរ **តទៅទំព័រទី ០៩**

# ខុមហ្វ្រែលសង្ឃឹមថា នឹងមានការកែទម្រង់ មុនការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រនៅឆ្នាំនេះ

**Lauren Crothers និង កាំង ម៉េងហ៊ុន**

គណកម្មាធិការសម្រាប់ការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (ខុមហ្វ្រែល) មាន"ទំនុកចិត្ត"ថា អនុសាសន៍ដែលខ្លួនបានស្នើទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតនៅឆ្នាំនេះកាន់តែមានតម្លាភាព ។

លោក គល់ បញ្ញា នាយកប្រតិបត្តិខុមហ្វ្រែល បានមានប្រសាសន៍កាលពីថ្ងៃសុក្រនៅឯកិច្ចពិភាក្សាចុងក្រោយរយៈពេល២ថ្ងៃជាមួយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតស្តីពីអនុសាសន៍របស់ខ្លួនថា "នេះជាការពិភាក្សាបើកចំហរ" ។

"គណកម្មាធិការជាតិរៀបចំការបោះឆ្នោតបានស្តាប់យើង ហើយយើងបានព្យាយាមការពារអនុសាសន៍របស់យើងទៅតាមក្របខណ្ឌច្បាប់ដែលមានស្រាប់ ។ បញ្ហាមួយចំនួនក្នុងចំណោមបញ្ហាទាំងនេះតែងតែកើតមានឡើងអំឡុងពេលបោះឆ្នោត" ។

លោក បញ្ញា បានមានប្រសាសន៍ថា លោកជឿថា គណកម្មាធិការជាតិរៀបចំការបោះឆ្នោតទទួលយកមតិអ្នកដ៏ទៃច្រើនជាងមុនទំនងជាដោយសារតែអន្តរជាតិមានការចាប់អារម្មណ៍ចំពោះការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រដែលនឹងប្រព្រឹត្តឡើងនៅថ្ងៃ ទី២៨ ខែកក្កដានេះ ។

លោក បញ្ញា មានប្រសាសន៍ថា "ពេលនេះពួកគេកំពុងស្តាប់យើង ។ ខ្ញុំគិតថា វាជាពេលដែលគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតគួរតែយកចិត្តទុដាក់ ពីព្រោះសហគមន៍អន្តរជាតិពួកគេកំពុងឃ្លាំមើលស្ថានភាពនៃការបោះឆ្នោតនៅពេលខាងមុខនេះដោយប្រុងប្រយ័ត្ន" ។

កង្វល់មួយក្នុងចំណោមកង្វល់ដែលបន្ទាន់បំផុតសម្រាប់ខុមហ្វ្រែល គឺថា ត្រូវតែទប់ស្កាត់មិនឱ្យមានកងកម្លាំងប្រដាប់អាវុធ ឬនគរបាលដែលត្រូវនៅជាអព្យាក្រិតនោះចូលរួមធ្វើការឃោសនាបោះឆ្នោតដោយខុសច្បាប់ ។

**តទៅទំព័រទី ០៩**

# Oxcart Races Mark End of Rice Harvest

*By Mech Dara - February 18, 2013*

An estimated 200 people turned out yesterday to watch the annual oxcart racing competition in Kompong Speu province to mark the end of the rice harvest season. Meas Path, one of the organizers of the event, said it was tradition to hold the oxcart races after the rice harvest—which wrapped up at the end of January.

"We do this after every harvest and try to keep it for the younger generation so they can learn about our traditions," he said, adding that the 30 oxcarts and their intrepid drivers had raced along a 1.5-km track.

There was no clear winner, as the races are just for fun, he said.

Sroy Samreth, 31, who said he takes part in the event every year, said he had been training for about a month ahead of the competition.

"I feel very proud to be one of the racers," he said, but warned that the race track could be precarious.

"If you don't train your oxen well, it can be dangerous," he said.

"After harvesting our rice crops, we trained our oxen for about a month so that they are familiar with the track. If we hadn't, they could run off the track and the carts could overturn," he added.

Mok Theum, 66, said the races showed villagers still respected tradition despite modern changes to farming methods.

"We hold the festival to celebrate the end of the harvest and pay our respects to the earth and water spirits," he said.

"Now, we use machines in harvesting but before, we used cows and buffalos," he added.

# Appeal Court Sets March Date for Sonando Retrial

*The Cambodia Daily*

The Appeal Court has set a date for the retrial of independent radio station owner Mam Sonando, who was sentenced to 20 years in jail by the claims was his encouragement of a rural uprising. Mr. Sonando's appeal hearing is scheduled for March 5, Appeal Court Judge Khun Leangmeang said . Mr. Sonando's lawyer, Sa Sovan, said he had received the court's letter setting the date of the retrial on Thursday. Mr Sovan delined to comment furthr, citing a recent gag order from the Cambodian Bar Association ordering all lawyers to seek and receive the association's perminssion before speaking with the media.

Mr. Sonando, the owner of beehive Radiio station, was convicted on six counts relating to accusations that he helped, through verbal means, vilagers in Kratie province in their attempt to break away from state control. International and local human rights group have condemned both the allegations against Mr. Sonando and his lengthy conviction. The only victim of the so-called rebellion was a 14-year-old girl who was killed by sate security forces when they raided Broma vilage in May to evict hundreds of families involved in a long-running land dispute with a rubber plantation. Authorities have refused to investigate the girl's killing, dismissing it as a simple "accident."

**តមកពីទំព័រទី ២**

# សម រង្ស៊ី ត្រូវត្រឡប់ទៅកម្ពុជា...

លោក ហ៊ុន សែន អាយុ៦១ឆ្នាំបានឡើងកាន់អំណាចតាំងពី១៩៨៥ ក្រុមសិទ្ធិមនុស្សនិយាយថា លោកធ្លាប់បានគាបសង្កត់លើបក្សប្រឆាំង ។ -ឆ្នាំ ២០០៨ គណបក្សប្រជាជនរបស់លោក (CPP) បានឈ្នះអាសនៈ៩០ក្នុង១២៣ គណបក្សសម រង្ស៊ី បាន២៦ និងគណបក្សសិទ្ធិមនុស្សបាន៣អាសនៈ ។

ប្រទេសបារាំងតាមរយៈនាយករដ្ឋមន្ត្រីហ្សង់ម៉ាក់ អេរ៉ូ កាលពីបូជាបុណ្យសពសម្តេចសីហនុ និងសហរដ្ឋអាមេរិក តាមរយៈប្រធានាធិបតីបារ៉ាក់អូបាម៉ា កាលពីឱកាសប្រជុំអាស៊ានបានបង្ហាញថា "ចង់ឃើញការបោះឆ្នោតដោយមានលោក សម រង្ស៊ី ចូលរួមនៅកម្ពុជា" ដល់លោក ហ៊ុន សែន នាយក រដ្ឋមន្ត្រីខ្មែរ នាទីក្រុងភ្នំពេញរួចមកហើយ ៕ **ខ្មែរផុស ស.រ.អា**



អ្នកឧបត្ថម្ភ

# សុខភាព និងម្ហូបអាហារយើងបរិភោគ

## សម្លម្ជូរគ្រឿងសាច់គោ

### គ្រឿងផ្សំ

- ពោះគោ ១/៤ ផោន

គ្រឿង

- ស្លឹកគ្រៃ ៣ គល់ហាន់ឲ្យស្តើងៗ
- ម្សៅរមៀត ១ ស្លាបព្រា
- ម្ទេងកិនល្អិតៗ ២ ស្លាបព្រា
- ស្លឹកក្រូច ៥ សន្លឹកហាន់ល្អិតៗ
- អំបិល ១/២ ស្លាបព្រា
- ខ្ទឹមស ៤ កំពឹស
- សាច់ចន្លុកគោ ១២ អោនស៍, យកសាច់សុទ្ធ, ចៀរខ្លាញ់ចោល, ហាន់ឲ្យស្តើងៗ
- ទឹកត្រី ១ ស្លាបព្រា
- ប្រេងកាណូឡា ១ ស្លាបព្រា
- ទឹកសុទ្ធ ៤ ពែង
- ត្រប់ស្រួយ ១០ ផ្លែ, ផ្លែនិមួយៗពុះជាពីរ ឬជាបួន
- ផ្សិត ១/២ ផោន ផ្សិតនិមួយៗពុះជាបី ឬជាបួន
- ម្សៅម្ជូរអំពិល ២ ស្លាបព្រា
- ម្ទេស ចាឡាពីញ៉ូ ៣ ផ្លែកាត់តូចៗ
- ស្លឹកម្រះព្រៅ ១ ពែង

រៀបចំសំរាប់មនុស្ស : ៥ នាក់
បរិមាណបរិភោគ : សម្ល ២ ចាន និងបាយអង្ករសំរូប ១ ចាន

**ការរៀបចំ :**

ស្រុះពោះគោប្រហែល ២០-៣០ នាទី។ ខណៈដែលពោះគោកំពុងស្រុះ, កិនស្លឹកគ្រៃ, រមៀត, ម្ទេង, ស្លឹកក្រូច, ខ្ទឹមស និងអំបិលដោយប្រើម៉ាស៊ីនកិន ឬត្បាល់បុកឲ្យបានហ្មត់ល្អ ។

នៅពេលពោះគោស្ងោរឆ្អិនហើយ, ហាន់វាឲ្យស្តើងៗ ហើយហាន់សាច់គោជាដុំៗប៉ុនមេដៃ ។

ដាក់ខ្ទះលើចង្ក្រានឲ្យក្តៅ ហើយចាក់សាច់គោ, ពោះគោដែលហាន់រួចហើយ, គ្រឿងផ្សំ និងទឹកត្រីចូល ។ ចំអិនប្រហែល ៥ នាទីដើម្បីឲ្យសាច់គោប្រែពណ៌ និងដើម្បីឲ្យគ្រឿងផ្សំចេញខ្លិនក្រអូប ។ ចាក់ទឹកចូល ហើយរំងាស់ប្រហែលមួយម៉ោង ទាល់តែសាច់គោ និងពោះគោផុយល្អ ។

ខណៈគ្រឿងនិងសាច់កំពុងតែរំងាស់, លាង ហើយហាន់ត្រប់, ផ្សិត, ម្ទេសចាឡាពីញ៉ូ, និងស្លឹកម្រះព្រៃ ។

បន្ទាប់ពីគ្រឿងនិងសាច់រំងាស់អស់រយៈពេលមួយម៉ោងហើយ ដាក់ផ្សិតចូល ហើយចំអិន ១០ នាទី ។ ដាក់ម្សៅអំពិល, ត្រប់ និងម្ទេសដែលហាន់រួចហើយចូល និងចំអិន ១០ នាទីទៀត ។ ចុងក្រោយបង្អស់ ដាក់ម្រះព្រៅចូល ហើយបិទភ្លើង ។

បរិភោគជាមួយ : បាយអង្ករសំរូប ៥ ពែង

**កំណត់សំគាល់អាហារូបត្ថម្ភ**

- បន្ថយជាតិសូឌីយ៉ូម (កុំដាក់អំបិល និងម្សៅស៊ុប, ប្រើទឹកត្រីតិច)
- បន្ថយជាតិខ្លាញ់ឆ្អែត និងជាតិកូលេស្តេរ៉ូល (ប្រើសាច់គោតិច, ប្រើសាច់គោគ្មានខ្លាញ់ ជំនួសសាច់គោខ្លាញ់ច្រើន)
- បង្កើនជាតិសរសៃ និងបន្ថយជាតិកាបូអ៊ីដ្រាតធម្មតា

## Sour Lemongrass Beef Soup

*Ingredients/Shopping list*

¼ pound cow stomach

*Paste*
3 stalks lemongrass, thinly sliced
1 teaspoon turmeric
2 tablespoons galangal, finely chopped
5 lime leaves, chopped
½ teaspoon salt
4 cloves garlic
12 ounces boneless top sirloin or top round, sliced thinly, all fat removed (select grade)

1 tablespoon fish sauce
1 tablespoon canola oil
4 cups water
10 small Asian eggplants, halved (20 halves or quarters if from larger eggplants)
½ pound cello mushrooms, sliced into thirds, then halved, then ⅓ inch slices with the grain of the mushroom
2 teaspoons tamarind soup base (Dragonfly brand)
3 jalapeno peppers, sliced
1 cup holy basil leaves (mareh prew), separated from the stems OR fried curry leaves

Serves 5 generously
Serving size: 2 cups soup, 1 cup cooked brown rice

*Preparation*

Boil the cow stomach about 20-30 minutes. While the stomach is boiling, grind the lemongrass, turmeric, galangal, lime leaves, salt and whole garlic cloves in a grinder or blender or with a mortar and pestle to make a fine paste.

When the stomach is cooked, slice it thinly (about ¼ inch slices) so that the folds fan out along the base.

Heat the oil in a wok and add the sliced meat, sliced stomach, paste, and fish sauce. Cook for about 5 minutes to brown the beef and release the aroma of the paste. Add the water and cook about 1 hour, until the meat and stomach are very tender.

While the base is boiling, wash and prepare the eggplant, mushrooms, jalapeno peppers, and holy basil leaves.

After the base has boiled for 1 hour, add the mushrooms, and cook for 10 minutes. Add the tamarind base, eggplants, and sliced peppers, and cook 10 minutes. Turn off the heat and add the holy basil or fried curry leaves.

*Serve with*

- 5 cups cooked brown rice

*Nutrition Notes*

- Reduced sodium (less salt, no MSG, less fish sauce)
- Reduced saturated fat and cholesterol (less beef, lean beef instead of higher-fat cut)
- Increased fiber/reduced simple carbohydrate (brown rice instead of white rice)

## ឆាគ្រឿងសាច់មាន់

### គ្រឿងផ្សំ

គ្រឿង

- ស្លឹកគ្រៃ ២ គល់ ហាន់ល្អិតៗ
- ខ្ទឹមស ២កំពឹសធំៗ ចិញ្ច្រាំល្អិតៗ
- មើមខ្ទឹមក្រហម ២ ដុំចិញ្ច្រាំល្អិតៗ
- ម្ទេង ១ កង់កាត់ដុំតូចៗ
- ម្សៅរមៀត ១ ស្លាបព្រា
- ទឹក ១/៤ ពែង
- ស្លឹកកន្ទ្រោក និង/ ឬ ស្លឹកម្រះព្រៅ ១ កញ្ចប់
- ប្រេងខាណូឡា ២ ស្លាបព្រា
- ទ្រូងមាន់យកស្បែកចេញ ហាន់ដុំៗ ១២ អោនស៍
- ស្ករ ១.៥ ស្លាបព្រា
- ទឹកត្រី ១/២ ស្លាបព្រា
- អំបិល ១/២ ស្លាបព្រា
- ទឹក ១/២ ស្លាបព្រា
- ម្ទេស ចាឡាពីញ៉ូ ៥ ផ្លែ ហាន់ល្អិតៗ
- ម្ទេស Cubennelle កាត់ចំណិតត្រសក់
- មើមខ្ទឹមក្រហម(onion) ហាន់ចំណិតៗ
- ម្រះព្រៅ ១កែវ

រៀបចំសំរាប់មនុស្ស : ៤ នាក់
បរិមាណបរិភោគ : ឆាសាច់មាន់ និងបន្លែ ១.៥ ចានជាមួយបាយអង្ករសំរូប ១ ចាន

**ការរៀបចំ :**

កិនគ្រឿងផ្សំជាមួយនឹងម៉ាស៊ីនកិន ឬត្បាល់បុកឲ្យហ្មត់ ។ គ្រឿងផ្សំនេះ គឺដូចជាគ្រឿងផ្សំរបស់សម្លម្ជូរគ្រឿងដែរ ។

កំដៅប្រេងក្នុងខ្ទះ ហើយដាក់គ្រឿងចូល ។ ចំអិនប្រហែល ៥ នាទី ។ ដាក់សាច់មាន់, ស្ករ, ទឹកត្រី, អំបិល, និងទឹកកន្លះពែង, កូរឲ្យសព្វល្អបន្ទាប់ពីដាក់គ្រឿងបន្ថែមនិមួយៗចូល ។ ចំអិនទាល់តែសាច់មាន់ជិតឆ្អិន ប្រហែលជា ៥ នាទី ហើយដាក់ម្ទេស និងខ្ទឹមបារាំងចូល ។ ចំអិន ៥ នាទីទៀត ទាល់តែម្ទេសនិងខ្ទឹមបារាំងទន់ ប៉ុន្តែនៅស្រួយច្រុបៗ ។ ចុងក្រោយបង្អស់ដាក់ស្លឹកម្រះព្រៅ និង/ ឬ ស្លឹកកន្ទ្រោកដែលរំលីងឬអាំងរួចចូលក្នុងឆ្នាំង ។

បរិភោគជាមួយ : បាយអង្ករសំរូប ៤ ពែង

**កំណត់សំគាល់អាហារូបត្ថម្ភ**

- បន្ថយជាតិសូឌីយ៉ូម (ប្រើទឹកត្រី និងអំបិលតិច)
- បន្ថយជាតិខ្លាញ់ឆ្អែត និងជាតិកូលេស្តេរ៉ូល (ប្រើប្រើសាច់ទ្រូងមាន់ចៀរស្បែកចេញ ជំនួសសាច់គោ ឬសាច់ជ្រូក។
- បង្កើនជាតិសរសៃ និងបន្ថយជាតិកាបូអ៊ីដ្រាតធម្មតា (បរិភោគបាយអង្ករសំរូប ជំនួសបាយអង្ករសរិត)



## Spicy Lemongrass Stir Fry with Chicken

*Ingredients/Shopping list*

*Paste*
2 stalks lemongrass, finely sliced
2 garlic cloves, chopped
1 medium onion or 2 shallots, chopped
1 inch section galangal, peeled and chopped
1 teaspoon turmeric
¼ cup water
1 cup curry leaf, loosely packed OR 1 cup holy basil

2 tablespoons canola oil
12 ounces (¾ pound) boneless skinless chicken breast, cut into thin slices
1½ tablespoons sugar
½ tablespoon fish sauce
½ teaspoon salt
½ cup water
5 jalapeno peppers, sliced (about 1 cup)

Serves 4
Serving size: 1½ cups chicken and vegetables, 1 cup cooked brown rice

*Nutrition Notes*

- Reduced sodium (less fish sauce, less salt)
- Reduced saturated fat and cholesterol (skinless chicken breast instead of beef or pork)
- Increased fiber/reduced simple carbohydrate (brown rice instead of white rice)

*Preparation*

Grind the ingredients for the paste in a grinder or blender or pound them with a mortar and pestle to a fine paste..

Heat the oil in a wok, and add the paste and the curry leaves (if using curry leaves). Cook for about 5 minutes. Add the chicken, sugar, fish sauce, and salt, and ½ cup water, stirring with each addition. Cook until the chicken is almost done, about 5 minutes, and add the peppers and onions. Cook about 5 minutes more, until the peppers and onions start to soften, but are still a bit crunchy.

You can also add holy basil at the end and omit the curry leaves, if you prefer.

*Serve with*

- 4 cups cooked brown rice

*Nutrition Notes*

- Reduced sodium (less fish sauce, less salt)
- Reduced saturated fat and cholesterol (skinless chicken breast instead of beef or pork)
- Increased fiber/reduced simple carbohydrate (brown rice instead of white rice)



## ណែមឆៅ

### គ្រឿងផ្សំ

- សំបកណែម ១២ បន្ទះ
- សរសៃនំបញ្ចុក ៣ អោនស៍
- ទ្រូងមាន់យកស្បែកចេញ ៥ អោនស៍
- សាឡាត់ហាន់ល្អិតៗ ២ ពែង
- ត្រសក់១ ផ្លែ ចិតសំបកចេញ ហើយចិតទ្រវែងៗ
- ជីរក្រហម ១/២ ចានវាល់

តទៅលេខក្រោយ

ឌឹ ខេមបូឌា ដេលី The Cambodia Daily

ដំណឹងប្រែសម្រួលពីភាសាអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ខេមបូឌា ដេលី ច្បាប់ចេញផ្សាយថ្ងៃ ច័ន្ទ ទី១៨ ខែ កុម្ភៈ ឆ្នាំ២០១៣

# សាលាឧទ្ធរណ៍នឹងបើកសវនាការជំនុំជម្រះ រឿងក្ដី លោក ម៉ម សូណង់ដូ ឡើងវិញនៅ ខែមីនា

**ខេមបូឌា ដេលី**

សាលាឧទ្ធរណ៍បានកំណត់កាលបរិច្ឆេទសម្រាប់បើកសវនាការជំនុំជម្រះឡើងវិញក្នុងរឿងក្ដីលោក ម៉ម សូណង់ដូ ម្ចាស់ស្ថានីយឯករាជ្យមួយដែលត្រូវបានសាលាដំបូងរាជធានីភ្នំពេញផ្ដន្ទាទោសឱ្យជាប់ពន្ធនាគាររយៈពេល២០ឆ្នាំកាលពីក្នុងខែតុលា ចំពោះអ្វីដែលរដ្ឋាភិបាលអះអាងថា លោកបានជំរុញឱ្យមានចលនាបះបោរនៅជនបទ ។

លោក ឃុន លាងម៉េង ចៅក្រមសាលាឧទ្ធរណ៍មានប្រសាសន៍កាលពីម្សិលមិញថា សាលាឧទ្ធរណ៍នឹងបើកសវានាការជំនុំជម្រះរឿងក្ដីលោក ម៉ម សូណង់ដូ នៅថ្ងៃទី៥ ខែមីនា ។

លោក ស សុវណ្ណ មេធាវីរបស់លោក ម៉ម សូណង់ដូ បានមានប្រសាសន៍ថា កាលពីថ្ងៃព្រហស្បត៍ លោកបានទទួលលិខិតរបស់តុលាការជូនដំណឹងពីការកាលបរិច្ឆេទបើកសវានាការជំនុំជម្រះឡើងវិញ ។

លោក សុវណ្ណ បដិសេធមិនធ្វើអត្ថាធិប្បាយថែមទៀតទេ ព្រោះនៅពេលថ្មីៗនេះមានបទបញ្ជាពីគណៈមេធាវីកម្ពុជាមិនឱ្យមេធាវីធ្វើអត្ថាធិប្បាយសាធារណៈឡើយ ហើយបានបង្គាប់ឱ្យមេធាវីទាំងអស់ស្វែងរក និងទទួលការអនុញ្ញាតពីគណៈមេធាវីជាមុនសិនមុននឹងនិយាយជាមួយប្រព័ន្ធផ្សព្វផ្សាយ ។ លោក ម៉ម សូណង់ដូ ម្ចាស់ស្ថានីយវិទ្យុសម្បុកឃ្មុំត្រូវបានផ្ដន្ទាទោសតាមបទចោទប្រកាន់ចំនួនប្រាំមួយករណីទាក់ទងនឹងការចោទប្រកាន់ថា លោកបានតាមរយៈពាក្យសម្ដីឱ្យអ្នក



ភូមិនៅក្នុងខេត្តក្រចេះប៉ុនប៉ងបំបែកខ្លួនចេញពីការគ្រប់គ្រងរបស់រដ្ឋ ។

អង្គការសិទ្ធមនុស្សជាតិ និងអន្តរជាតិបានថ្កោលទោសទាំងការចោទប្រកាន់លោក សូណង់ដូ និងការផ្ដន្ទាទោសលោករយៈពេលយូរនេះ ។

មានជនរងគ្រោះតែម្នាក់គត់ពីអ្វីដែលគេហៅថា ជាការបះបោរនេះ គឺក្មេងស្រីអាយុ១៤ ឆ្នាំម្នាក់ដែលបានកងកម្លាំងសន្តិសុខរបស់រដ្ឋបាញ់សម្លាប់នៅពេលពួកគេសម្រុកចូលភូមិប្រមាកាលពីក្នុងខែឧសភា ដើម្បីបណ្ដេញប្រជាពលរដ្ឋរាប់រយគ្រួសារដែលពាក់ព័ន្ធក្នុងជម្លោះដីធ្លីជាយូរមកហើយជាមួយក្រុមហ៊ុនចម្ការកៅស៊ូមួយ ។

អាជ្ញាធរបដិសេធមិនធ្វើការស៊ើបអង្កេតកាលសម្លាប់ក្មេងស្រីនេះទេ ដោយចាត់ទុកថា នេះជា"គ្រោះថ្នាក់"ចៃដន្យប៉ុណ្ណោះ ៕

**ប្រែសម្រួលដោយ ចេវ ប៊ុននី**

# ថ្ងៃសម្ពោធអណត្តិទី២ នៃប្រធានាធិបតី មានខ្មែរស្ម័គ្រចិត្តជួយដែរ

Lowell MA : លោកប្រធានាធិបតី បារ៉ាក់ អូបាម៉ា បានសម្ពោធអណត្តិថ្មីទី២ របស់លោកនៅថ្ងៃទី២០ មករា ឆ្នាំ២០១៣ ។ លោក វដ្ឋា យ៉ែម ភរិយានិងកូនស្រីទៅពីឡូវែលស្ថិតនៅក្នុងចំណោមក្រុម ដែលត្រូវទៅត្រួតពិនិត្យសន្តិសុខនៅច្រកចូលវិមានវ៉ាស៊ីនតោន ។

កាលពី៤ឆ្នាំមុន នៅឧសភាសម្ពោធអណត្តិទី១ របស់លោក បារ៉ាក់ អូបាម៉ា មានទស្សនិកជន



អ្នកស្ម័គ្រចិត្តបំរើការ១៥,០០០នាក់ ដែលបានជ្រើសរើសក្នុងចំណោម៥៧,០០០នាក់ សម្រាប់ថ្ងៃសម្ពោធនោះ ។ បន្ទាប់ពីឆែកពីអតីតកាលដោយក្រុមសម្ងាត់សេតវិមានរួចហើយ លោក វដ្ឋា បានត្រូវចាត់តាំងជាមេក្រុមម្នាក់ក្នុងចំណោម១៨០០ ១,៨លាននាក់ ចូលរួមអបអរសាទរ -នៅឱកាសសម្ពោធទី២នេះ លោក យ៉ែម វដ្ឋា មានភារៈកិច្ចដ៏ខ្ពង់ខ្ពស់មួយ គឺការពារសន្តិសុខដល់ពលរដ្ឋដ៏ច្រើនរាប់សែននាក់ដែលមកវិមានកាលពីតូលជាថ្មីម្ដងទៀតនេះ ។ **តទៅទំព័រទី ២០**

**តមកពីទំព័រទី 06**

## ខុមហ្វ្រែលសង្ឃឹមថា នឹងមានការកែទម្រង់...

លោក បញ្ញា បានលើកឡើងថា ច្បាប់បោះឆ្នោតហាមប្រាមទង្វើបែបនេះយ៉ាងច្បាស់ ប៉ុន្តែខុមហ្វ្រែលបានសង្កេតឃើញមានការរំលោភច្បាប់ពេលកន្លងមក ។ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវស្កាត់ទង្វើបែបនេះ ដើម្បីពង្រឹងច្បាប់ដែលមានស្រាប់ ។

លោកបានបន្តថា "ពួកគេអាចចេញលិខិតព្រមានចំពោះបុគ្គលណាម្នាក់ ឬស្ថាប័នណាមួយដែលរំលោភច្បាប់ ឬដាក់ទោសពួកគេតាមរយៈការពិន័យ ឬបញ្ជូនពួកគេទៅតុលាការ ។ ខ្ញុំគិតថា គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមានអំណាច" ។

ដោយទាក់ទងបានតាមទូរស័ព្ទលោក ទេព នីថា អគ្គលេខាធិការគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមិនធ្វើអត្ថាធិប្បាយទេ ពេលលោកកំពុងវាយតម្លៃពីកិច្ចប្រជុំនេះ ដែលមានការចូលរួមពីសំណាក់សមាជិកគណបក្សប្រឆាំង ប៉ុន្តែមិនមានសមាជិកគណបក្សប្រជាជនកម្ពុជាដែលកំពុងកាន់អំណាចមកចូលរួមនោះទេ ។

លោក ទេព នីថា បានមានប្រសាសន៍ថា "យើងបានពិភាក្សាអំពីអនុសាសន៍ទាំង១៦ចំណុច ។ ខុមហ្វ្រែល និងគណបក្សនានាបានលើកឡើងពីហេតុផលរបស់ខ្លួនក្នុងការពិភាក្សានេះ ហើយយើងស្ដាប់ពួកគាត់" ។

លោកបានបន្តថា គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានកត់ត្រា ហើយនឹងពិភាក្សាចំណុចទាំងឡាយដែលសមាជិករបស់ខ្លួនបានលើកឡើងមុនពេលសម្រេចអនុវត្តចំណុចណាមួយ ។

លោក គល់ បញ្ញា បានមានប្រសាសន៍ថា លោកសង្ឃឹមថា សេចក្ដីប្រកាសមួយនឹងចេញនៅសប្ដាហ៍ខាងមុខនេះ ៕

**តមកពីទំព័រទី 06**

## ប្រជាពលរដ្ឋប្រណាំងរទេះគោប្រចាំឆ្នាំ...

បានចូលរួមប្រណាំងតាមបណ្ដោយផ្លូវលំចម្ងាយមួយគីឡូម៉ែត្រកន្លះ ។

លោកបន្ថែមថា ក្នុងការប្រណាំងនេះមិនមានអ្នកឈ្នះ និងមិនមានអ្នកចាញ់ទេ ដោយសារការប្រណាំងនេះគ្រាន់តែជាការកម្សាន្តសប្បាយប៉ុណ្ណោះ ។

លោក ស្រួយ សារិទ្ធ អាយុយ៣១ឆ្នាំ ដែលបាននិយាយថា លោកបានធ្លាប់ចូលរួមក្នុងព្រឹត្តិការណ៍នេះជារៀងរាល់ឆ្នាំនោះបាននិយាយថា លោកបានបង្វឹកគោរបស់លោករយៈពេលមួយខែនៅមុនពេលចាប់ផ្ដើមការប្រកួតប្រជែងនេះ ។

លោកបាននិយាយថា "ប្រសិនបើអ្នកមិនបានបង្វឹកគោរបស់អ្នកឱ្យបានល្អទេ គឺវាគ្រោះថ្នាក់ខ្លាំងណាស់" ។

លោក ម៉ុក ធឿន អាយុ៦៦ឆ្នាំ បានមានប្រសាសន៍ថា "បន្ទាប់ពីរដូវច្រូតកាត់បានបញ្ចប់រួចរាល់ហើយ យើងបានបង្វឹកគោរបស់យើងរយៈពេលប្រហែលមួយខែ ធ្វើដូច្នេះគោរបស់យើងស៊ាំជាមួយនឹងផ្លូវលំនោះ ហើយប្រសិនបើយើងមិនបានបង្វឹកគោរបស់យើងឱ្យបានល្អទេ នោះពួកវាអាចរត់ខុសផ្លូវ ហើយម្យ៉ាងវិញទៀតរទេះអាចក្រឡាប់មិនខានឡើយ" ។

លោកមានប្រសាសន៍បន្តថា អ្នកភូមិនៅតែគោរព និងស្រលាញ់ប្រពៃណីនៃការប្រណាំងរទេះគោនេះខ្លាំងណាស់ ទោះបីជាមានការផ្លាស់ប្ដូរក្នុងវិធីសាស្ត្រនៃការធ្វើកសិកម្មក៏ដោយ ។

លោកមានប្រសាសន៍បន្ថែមថា "បច្ចុប្បន្ននេះយើងបានប្រើប្រាស់គ្រឿងចក្រក្នុងការប្រមូលផលស្រូវ ប៉ុន្តែកាលពីសម័យមុនយើងបានប្រើគោ ឬក្របីក្នុងការប្រមូលផលដំណាំរបស់យើង" ។

**ប្រែសម្រួលដោយ យិន ណៃ**

LOWELL ELDER CARE 978-596-1111

# មជ្ឈមណ្ឌលថែទាំមនុស្សចាស់ក្រុងឡូវែល

345 Chelmsford St. Lowell, MA 01851/ 978-596-1111 – www.lowelleldercare.com

## អ្វីទៅជាមណ្ឌលថែទាំមនុស្សចាស់ក្រុងឡូវែល?

គឺជាលំនៅដ៏កក់ក្តៅមួយ ដែលផ្តល់សេវាមានកម្មវិធីជាក់លាក់ដល់សហគមន៍បំណង គឺគាំទ្រឲ្យមនុស្សចាស់ជរាអាចរស់នៅដោយឯករាជ្យខ្លួនឯង និងជួយឲ្យមានសុខុមាលភាពផ្នែកផ្លូវកាយ ផ្លូវចិត្ត និងផ្នែកសង្គម ។ កម្មវិធីរបស់យើងធានានូវបរិស្ថានរស់នៅមួយប្រកបដោយសុវត្ថិភាព និងមានបរិយាកាសដូចជាផ្ទះរបស់ពួកគាត់ ។

## ទីតាំងនៃមណ្ឌល

ទីតាំងអាចរកឃើញដោយងាយក្នុងអគារថ្មី ជាមួយនូវការតុបតែងរចនាបែបសិល្បៈខ្មែរយ៉ាងល្អប្រណិត ។ មានបន្ទប់ទទួលទានអាហារស្អាត និងមានពន្លឺគ្រប់គ្រាន់ បន្ទប់អានសៀវភៅ បន្ទប់កុំព្យូទ័រ បន្ទប់សម្រាក បន្ទប់មើលភាពយន្ត និងកន្លែងផ្សេងៗទៀតជាទីពេញចិត្តរបស់លោកអ្នក ។





## មណ្ឌលផ្តល់សេវាដល់មនុស្សចាស់

- មានរថយន្តជូនដំណើរទៅវិញទៅមកពីផ្ទះលោកអ្នក
- ការពិនិត្យ និងថែទាំសុខភាព
- ការព្យាបាលតាមរយៈការហាត់ប្រាណ
- កិច្ចការសង្គម (ផ្តល់ការពិគ្រោះផ្ទាល់ខ្លួន និងក្រុមគ្រួសារ)
- ម្ហូបខ្មែរក្តៅៗ និងចំណីផ្សេងៗ
- ការហាត់ប្រាណសំរាប់សុខភាពរាងកាយ
- កម្មវិធីសិល្បៈ និងតន្ត្រី
- ការអប់រំពីសុខភាព
- ការពិភាក្សាលើព្រឹត្តិការបច្ចុប្បន្ន (និងការសំណេះសំណាលគ្នា)
- សកម្មភាព និងដំណើរកំសាន្តក្រៅមណ្ឌល

## Our Services

- Door-to-Door Transportation
- Medical Care and Support
- Physical Therapy
- Social Worker
- Khmer Meals and Snacks
- Adaptive Physical Exercise
- Music Programs
- Health Educational Seminars
- Discussions on current events, (and times of reminiscing)
- Outdoor Field Trips

**សូមហៅទៅលោក ខឿ រស 978 996 6127**






☑ មិនកាត់នាទី និងមិនផុតកំណត់
☑ សម្លេងឮច្បាស់ល្អទូរស័ព្ទទៅស្រុកខ្មែរ

**4.5¢ per min**

| | Bonus (10%) | Min |
|---|---|---|
| $10.00 | $1 | 224 |
| $20.00 | $2 | 448 |
| $50.00 | $5 | 1,122 |
| $100.00 | $10 | 2,244 |

**Buy here and get 10% more!**

Tel: (978) 942 1641/ (978) 656 8141
(267) 253 3947

www.cambodiaphonecard.us



SIM'S Home Improvement
Major Sim Enterprises, Inc.

# ជាងសំណង់តាស៊ីម



License#CS 88569 Registration#153685
978-452-7467 / 978-421-3672 / 978-420-8551
FREE ESTIMATES
60 Middlesex St. (Rte.110) Lowell. MA 01852

FULLY INSURED

Repairing •Remodeling •Additions
ជួសជុល កែលំអរ សង់បន្ថែម

- Kitchen ចង្ក្រានបាយ
- Livingroom បន្ទប់ទទួលភ្ញៀវ
- Bathroom បន្ទប់ទឹក
- Bedroom បន្ទប់ដេក
- Roofing ដំបូល
- Siding ជញ្ជាំង
- Window បង្អួច
- Door ទ្វារ
- Basement ជាន់នៅក្រោមដី
- Additions បន្ទប់បន្ថែម

Residential • Commercial • Industrial
ទទួលប្រាក់គ្រប់ប្រភេទ
Bank Loan, Insurance, Compensation, Credit Debit, Check &Cash
More information call: 1.978.452.7467

www.SimsHomeImprovement.com
Boreth@SimsHomeImprovement.com

# កូនពៅលោក ហ៊ុន សែន សម្លឹងកៅអីសភាជាតិ

**ភ្នំពេញៈ** ហ៊ុន ម៉ានី អាយុ៣០ឆ្នាំ កូនពៅលោក ហ៊ុន សែន បានទទួលការយល់ព្រមឱ្យឈរឈ្មោះនៅខេត្តកំពង់ស្ពឺ ដូចកូនសមាជិកគណបក្សប្រជាជនឯទៀតៗដែរ នេះជាសម្តីលោក ជាម យៀប ជាសមាជិកអចិន្ត្រៃយ៍នៃបក្សពោលថា "គឺជាទំពាំងស្នងឫស្សី" ដែលទៅជំនួសសមាជិកចាស់ៗដែលមកដល់ទីបញ្ចប់នៃវិជ្ជាជីវៈរបស់ខ្លួន ហើយកូនប្រសារប្រុសរបស់លោក ហ៊ុន សែន ម្នាក់ទៀត ក៏នឹងក្លាយជាបេក្ខជនសភាដែរ ។

ហ៊ុន ម៉ានី នៅក្នុងក្រុមការងារឪពុករបស់ខ្លួនដឹកនាំចលនាយុវជនស្ម័គ្រចិត្តយ៉ាងសកម្ម ជំនិតនឹងអ្នកកាន់អំណាចរបស់ខ្លួនកាន់តែខ្លាំងឡើយ ។ លោក ឡៅ ម៉ុងហៃ អ្នកវិភាគឯករាជ្យ បានប្រកាសឱ្យដឹងថា ពីការបង្កើតរាជ្យវង្សនយោបាយនេះថា "ខ្ញុំមិនមានការភ្ញាក់ផ្អើលអ្វីទេ ពីការដែលគាត់រៀបចំឱ្យកូនដើរតាមគាត់ក្នុងនយោបាយនោះ" រីឯលោក ខៀវ កាញ៉ារិទ្ធ ទាត់ចោលការទិទៀនតែទទួលស្គាល់ថា "គណបក្សប្រជាជនបន្ថែមយុវជនក្នុងជួររបស់ខ្លួន ដែលបានរៀបចំច្រើនឆ្នាំមកហើយ ។



កូនប្រុសច្បងលោក ហ៊ុន សែន ម្នាក់ទៀត ឈ្មោះ ហ៊ុន ម៉ាណែត បានឡើងឋានៈជាឧត្តមសេនីយ៍ផ្កាយពីរ កាលពីឆ្នាំ២០១១ ឥឡូវកាន់កងឯកភាពប្រឆាំងភេរវកម្មនៃក្រសួងការពារជាតិ ហើយក៏ជាមេញ្ជាការរងនៃកងអង្គរក្សឪពុករបស់ខ្លួនដែរ ។ នៅមានកូនប្រុសទី២ម្នាក់ទៀត ឈ្មោះ ហ៊ុន ម៉ានិត អាយុ ៣១ឆ្នាំ មានឋានន្តរស័ក្តិជាវរៈសេនីយ៍អនុប្រធាននៃកងឯកភាពយកការណ៍យោធាដ៏សំខាន់នៅកម្ពុជា ។

ដកស្រង់ពី AFPឡឺប៊ីទីស្ទរណាល់ ២១/២/១៣






តមកទំព័រទី ១

# វត្តខ្មែរឡូវែលឆ្លើយតបការចោទប្រកាន់...

សន្ទឹកសន្ធាប់របស់វត្តអារាម ។ អ្នកដើមចោទ គឺ លោក មាស សែម ធ្លាប់ឈរឈ្មោះជាបេក្ខជន ព្រឹទ្ធសមាជិកសភាអាមេរិកាំងនៅម៉ាសាឈូសែត



និងលោក សម្បត្ត ស៊ុម ទាំងពីរូបជាអតីតគណ កម្មាធិការវត្ត ។ ប្រជាពលរដ្ឋខ្មែរនៅឡូវែលមាន ការខ្មាសអៀននិងអំពើរបៀបនេះចេះតែកើត ផ្ទួនៗគ្នានៅក្នុងសហគមន៍ខ្មែរផុសក៏បានទៅថ្វាយ បង្គំសុំការពន្យល់ និងស្វែងរកការពិតពីព្រះអង្គ សៅ ឃន ព្រះអង្គបណ្ឌិតមហាបរិញ្ញា ញ៉ែម គិមសេង ជាអ្នក ជំនួយការ ព្រះអង្គ សាវ៉ាន់ ហុក ជាអគ្គលេខាធិការមកពីវត្តរ៉ូដអាយឡិន និង អ្នកស្រី ម៉ាយ៉ា មែន នៅវត្តសហគមន៍ព្រះសង្ឃ ខ្មែរ នាថ្ងៃអង្គារ៍បន្ទាប់មក ។

**សំនួរខ្មែរផុស :** រឿងអាស្រូវបានត្រូវចុះ ផ្សាយផ្ទួនៗគ្នាជាង១០ឆ្នាំមកហើយ ពីវត្តត្រៃ រតនារាម ដែលព្រះអង្គគង់ជាចៅអធិការ រហូត ដល់បោះបង់វត្តចាស់មកដល់វត្តខ្មែរឡូវែលមួយឆ្នាំ ហើយ រឿងនៅតែមិនចប់ តើព្រះអង្គវាយតម្លៃ ព្រឹត្តិការណ៍ថា ជាយ៉ាងណា?

**ព្រះតេជគុណ សៅ ឃន :** អាត្មាសូម ចំរើនពរខ្មែរផុស និងសូមអរគុណអ្នកអានកាសែត ដែលទទួលដំណឹងនេះទៅដល់នៅតំបន់ឡូវែល



និងតំបន់ដ៏ទៃ ជាដំបូងអាត្មាសូមរំលឹកថា អាត្មា មិនមានការវៃឆ្លាតខាងបច្ចេកវិជ្ជាទំនើបខាងប្រើ អ៊ីមែល ឬវេបសាយអ្វីទេ ដូចនេះប្រាកដជាមាន ការលំបាក និងរកជួបគ្នា ឬទាក់ទងគ្នាណាស់ ចំណែកឯរឿងរ៉ាវដែលបានបន្តជាង១០ឆ្នាំមក ហើយ អាត្មាក៏នឿយណាយណាស់ហើយ បានផ្ទេរ វត្តត្រៃរតនារាមឱ្យគណកម្មការវត្តរួចហើយទៅ ឱ្យគណកម្មការវត្តមកនៅវត្តខ្មែរឡូវែលដីថ្មី ហើយ ក៏នៅតែមិនចប់ ។ ទាក់ទងទៅនឹងទីថ្មីនេះមាន រឿងច្រណែនគ្នាឈ្លោះគ្នាប្រចណ្ឌគ្នាប្តីប្រពន្ធក្តី រឿងពលរដ្ឋខាងក្រៅដែលគេយកមកខ្វាក់ចោល ប្រៀបឧបមាដូចជំនាន់ដើម "ព្រឡុងខ្មោច" របស់ ចាស់ៗគេយកមកដាក់ឱ្យវត្ត ដូច្នេះរឿងអាក្រក់ ទាំងប៉ុន្មាន គេយកមកដាក់វត្តហ្នឹងឯង! មិនបាន សិក្សាពីសេចក្តីល្អរបស់វត្តនោះទេ -រឿងមួយ ទៀត គឺរឿងលុយកាក់វត្តហ្នឹងយើងមានបំណង ធ្វើឱ្យវត្តនេះក្លាយទៅជាគំរូគេក្នុងរឿងគ្រប់គ្រង ឱ្យបរិសុទ្ធវត្តយើងត្រូវការឱ្យមានសមត្ថភាព សមាជិកដែលបំពេញលក្ខណ:តាមមាត្រានៃ លក្ខន្តិកសហគមន៍បាននិមន្ត ព្រះសង្ឃ ញ៉ែម កិមតេង ដែលមានសមត្ថភាពខ្ពស់ឱ្យមកជួយ ដឹកនាំគម្រោងរៀបចំវត្ត -គណកម្មាធិការនាយក ក៏សុទ្ធតែព្រះសង្ឃសម្រាប់ធ្វើការដឹកនាំអង្គការ ព្រះសង្ឃ ពុំមានឧបាសិកាក្នុងហ្នឹងទេ មានឧបាសក ខ្លះ មកគ្រាន់តែមកជួយជាអ្នកស្ម័គ្រចិត្ត ខ្លះមក ជួយដែរ តែទាមទារឱ្យប្តូរការគ្រប់គ្រងលុយកាក អាត្មាថា "មិនបានទេ បើមិនមានការប្រជុំ និង សម្រេចពីគណកម្មការព្រះសង្ឃទេនោះ" ...ព្រះអង្គ ញ៉ែម គិមតេង អាចឱ្យយោបល់បានច្រើន ។

**ព្រះអង្គ ញ៉ែម គិមតេង :** អាត្មាមកជួយ នេះ ព្រោះអាត្មាយល់ថា សកម្មភាពសហគមន៍



ព្រះសង្ឃខ្មែរត្រូវតែបន្ត និងពង្រីកគោលជំហរ ឡើងវិញ -អាត្មាឃើញថា តែនៅសហរដ្ឋអាមេរិក នេះមាន១១៣វត្ត ហើយវត្តនិមួយៗឥតមានការ ទាក់ទងគ្នាទេ វត្តណាចង់ធ្វើអ្វីក៏ធ្វើទៅគ្មានចំណុះ នឹងវិន័យណាមួយទេ ។ បើនិយាយរួមទៅវាដូច គ្នាកាលពីសតវត្សរ៍ទី១៥-១៦ ដែលខ្មែរយើង បែកបាក់ខ្ចាត់ខ្ចាយ វត្តនិមួយៗរស់នៅដាច់ដោយ ឡែកពីគ្នាព្រះពុទ្ធសាសនាក្រោយពីបែក "លង្វែក" ទៅហើយ ក៏រតាត់រតាយវិន័យវត្តណាក៏សម្រាប់ តែវត្តហ្នឹងពីឃុំមួយទៅឃុំមួយសូត្រធម៌មិនត្រូវ គ្នាផង ដល់ចុះខ្សោយមែនទែនទៅអ្នកបួសខ្លះ ក៏ ធ្វើកូនកន្ត្រៃ ធ្វើតោក ធ្វើប្រអប់ស្លា ក៏បរទេះ គោទៅលក់តាមតំបន់ផ្សេងៗ លោកគ្រូមេវត្ត - ចៅអធិការបានក្លាយទៅជាលោកគ្រូសង្ឃរាជ ដែល គេហៅថា "សង្រ្គាច"តាំងពីពេលនោះមកដែល ជាអ្នកបញ្ញតិវិន័យតាមវត្តនិមួយៗនោះ ។ នៅស្រុក អាមេរិកនេះ បើគ្មានសហគមន៍ព្រះសង្ឃជាអ្នក ប្រមូលផ្តុំវត្តអារាមព្រះសង្ឃឱ្យនៅក្នុងវិន័យតែ មួយទេនោះ នឹងធ្លាក់ទៅរកដូចគ្នា និងសាសនា សតវត្សទី១៥-១៦នោះដែរ នាសម័យបែកលង្វែក នោះម្តងទៀតហើយ ។ អាត្មាមកនេះក៏ព្រោះតែ បានឃើញថា សហគមន៍ព្រះសង្ឃខ្មែរបានចាប់ កំណើតពីឆ្នាំ១៩៩៣ ដោយព្រះសង្ឃចាស់ទុំរួច ពីការកាប់សម្លាប់ជំនាន់ខ្មែរក្រហម នៃសង្រ្គាម ស្រុកខ្មែរក្តីមានសេចក្តីរីករាយណាស់ និងចូលរួម ព្រោះអីបានងើបម្តងហើយ ក៏ស្រុតចុះទៅវិញ ដោយ ខ្វះធនធានអាត្មាមកនេះមកជួយពង្រឹងការប្រ តិបត្តិធម៌ឡើងវិញ ក៏ដូចជាពង្រឹងសាសនានៅ ស.រ.អានេះដែរ ។

មួយវិញទៀតអាត្មាក៏មានការស្រងាកចិត្ត ដែរ កាលពីថ្ងៃអាទិត្យកន្លងទៅនេះ ដោយកាសែត "ឡូសាន់" ចុះផ្សាយពីវត្តខ្មែរឡូវែលយើងយល់ ថា ការផ្សាយនេះមិនពិត ពីព្រោះយើងដែលធ្វើ ការនៅទីនេះមិនបានឃើញរឿងអីដូចដែលកាសែត នោះនិយាយទេ ស្តាប់អ្នកពីបីនាក់នោះដែលនៅ ក្រៅរង្វង់អ្នកទទួលខុសត្រូវ ហើយចុះផ្សាយធ្វើ ឱ្យកើតភាពច្របូកច្របល់ជាអ្នកអុចអាលទៅ វិញ ដែលយើងមិនអាចទទួលយកបានដែរ ។

**សំនួរខ្មែរផុស :** តើព្រះអង្គប្រាប់បានទេថា ព្រះអង្គដឹងពីចលនាលុយចេញចូលទាំងអស់ ហើយអាចដឹងទេថា បើព្រះអង្គ សៅ ឃន លាក់ លុយដោយវិធីណាមួយព្រះអង្គនឹងដឹង?

**ព្រះអង្គ ញ៉ែម គិមតេង:** លុយនេះមិន អាចលាក់បានទេ លុយចូលពីការជាវព្រះមួយ ព្រះអង្គតម្លៃ $១០០ដែលមានការកត់ត្រាត្រឹម ត្រូវម្ចាស់លុយក៏ទទួលដំណឹងឆ្លើយតបពីប្រាក់ ជាវ ហើយប្រាក់សរុបយកទៅដាក់ធនាគារចា ឈ្មោះម្ចាស់លុយលើបល្លង្កព្រះពុទ្ធបដិមាថែម ទៀត ។

**សំនួរខ្មែរផុស :** តើលុយទាំងអស់ដាក់ទៅ ក្នុងធនាគារឬ?

**ព្រះអង្គ ញ៉ែម គិមតេង :** មិនទាំងអស់ទេ! ក្នុងពិធីនិមួយៗតែងមានការចំណាយ ដូចជាទៅ លើឈ្នួលទីកន្លែង ទៅលើការទិញ ទឹក ម្ហូប អាហារ ជួលប៉ូលិសជាដើម ដែលត្រូវចាយភ្លាមៗ ហើយចំណាយមួយចំនួនទៀត ត្រូវចាយជាសែក តែប្រាក់ចំណូលជិត៩០%ត្រូវបញ្ចូលគណនេយ្យ ធនាគារទាំងអស់ ។

**សំនួរខ្មែរផុស :** អត្ថបទឡូសាន់ និយាយថា ប្រាក់ចំណូល៤សែនដល់នៅធនាគារឃើញលុយ តែ៦ពាន់ តើព្រះអង្គពន្យល់យ៉ាងណា ?

**ព្រះអង្គ ញ៉ែម គិមតេង :** នេះជាការ បំភ្លើសមួយ យើងបានប្រកាសនាឱកាសប្រជុំប្រចាំ ឆ្នាំថ្ងៃ២២ ខែធ្នូ ថា ថវិកាក្នុងឆ្នាំនេះ ប្រមូលបាន គ្រប់ផ្នែកសរុប២សែន៩ម៉ឺនដុល្លារ ហើយកាសែត យកទៅចុះចំនួនប្រាំសែនដែលជាហេតុធ្វើឱ្យអ្នក អានច្រឡូកច្រឡំ -ហើយម្យ៉ាងទៀតខ្ចង់ចំណាយ របស់យើងសុទ្ធតែកត់ត្រាទាំងអស់បុណ្យនិមួយៗ សុទ្ធតែផ្សព្វផ្សាយអំពីបំណង ហើយត្រូវចាយ ឱ្យត្រូវតាមបំណងនៃពិធីនោះ ដូចជាថា បុណ្យផ្កា សម្រាប់ទៅសងថ្លៃដី គឺយើងយកលុយនោះទៅ សងថ្លៃដីនោះមិនមែនធ្វើអ្វីផ្សេងទេ ដូច្នេះហើយ បានជាលុយសល់តិច ពីព្រោះលុយចេញពីធនាគារ ទៅសងថ្លៃដី...

**សំនួរខ្មែរផុស :** ដូច្នេះបើគេអាចឃើញថា លុយសល់៦ពាន់ក្នុងធនាគារ តើគេអាចឃើញ ចំណាយបន្តបន្ទាប់នៅក្នុងគណនេយ្យឬទេ?

**ព្រះអង្គ ញ៉ែម គិមតេង :** យើងអាច ចំណាយដូចជាជាវព្រះអង្គ១បាន $១០០ក្នុង នោះ យើងមានចំណាយសំរាប់ជាងកសាងព្រះបដិមា ចំណាយលើមេធាវីចំណាយលើដីដែលជា"សែក" ចេញពីធនាគារ -ជាការពិត ហើយដែលថា ឃើញ លុយសល់៦ពាន់ ពីព្រោះលុយគេឱ្យមកសម្រាប់ ចំណាយ មិនសំរាប់យកមកបើកមើលទេ បើយើង មានចំណាយច្រើនមុខណាស់ គ្មានអ្វីសម្រាប់ លាក់លៀមទេ បើគេអាចឃើញថា លុយនៅ សល់តែ៦ពាន់ ក៏គេអាចឃើញចំណាយអ្វីបន្ត បន្ទាប់សម្រាប់ការងារកសាងវត្តដែរ ។ អាត្មាសោក ស្តាយដោយ"ឡូសាន់"ចុះផ្សាយអត្ថបទដោយ គ្រាន់តែឮមនុស្សពីរបីនាក់ និយាយអ្នកទាំងនោះ ពុំទាន់បានធ្វើអ្វីជាប្រយោជន៍ដល់សង្គមនៅឡើយ តែដល់អ្នកទាំងនោះលើកគ្នាមកជេរព្រះសង្ឃ ដល់កុដិសុទ្ធតែថា ព្រះអង្គ សៅ ឃន គ្មានសមត្ថភាព ឱ្យចុះចេញ! សរសេរសំបុត្រគម្រាម! បែរជាមិន ឃើញ"ឡូសាន់"ចុះអំពីអំពើព្រហើនមើលងាយ ព្រះសង្ឃពីអ្នកទាំងនោះទេ ។

**សំនួរខ្មែរផុស :** ខ្ញុំព្រះករុណាឮថា ដីដែល ព្រះអង្គទិញបានមានគម្រោងសង់អគារធំតូចមាន អាចមិនមានទទួលអនុញ្ញាតិឱ្យសង់ដោយនៅ លើដីហាមឃាត់ ?

**ព្រះអង្គ ញ៉ែម គិមតេង :** ដីយើងទិញ មាន១២អេគឺ នៅក្នុងនោះមានផ្នូរខ្មោចបុរាណ ដែលគេរក្សាទុកក្នុងទំហំដីមិនដល់១អេគឺទេ ដែល គេមិនឱ្យប៉ះពាល់ ឬសង់អ្វីពីលើ ផ្នែកឯទៀតៗ មិនប៉ះពាល់ទេ -ម្យ៉ាងទៀតតំបន់នោះគេហៅ ថា តំបន់ដែលធ្លាប់មានទឹកលិច (៥០ឬ១០០ឆ្នាំ ទើបមានម្តង) អាជ្ញាធរគេតម្រូវឱ្យយើងធ្វើ សំណង់ដោយគោរពលក្ខខណ្ឌនៃតំបន់ទឹកលិច របស់គេ ។

**សំនួរខ្មែរផុស :** អ្នកជិតខាងគេសប្បាយ ឬអន់ចិត្តពីវត្តមានរបស់វត្ត?

**ព្រះអង្គ ញ៉ែម គិមតេង :** ពីមុនគេមិន ស្គាល់យើង គេមានការបារម្ភក្រែងយកសាសនា មកដាក់ទីនេះនាំឱ្យមានការឈឺចាប់ ឬប៉ះពាល់ ដល់ការរស់នៅរបស់គេ ប៉ុន្តែក្រោយមកប្រឆាំង នេះជួយមកវិញ ដោយយល់ថា យើងមិនមែន ជាអ្នកបង្កបញ្ហាអីទេ -ឬក៏អំពើហិង្សាក៏គ្មាន គេ ត្រឡប់មកគាំទ្រវិញការតែច្រើន ។

**សំនួរខ្មែរផុស :** ខ្ញុំនៅតែមិនយល់ថា ហេតុ អ្វីកម្មពារអ្វី បានជារឿងបន្តពីវត្តមុនមកដល់វត្ត ខ្មែរដែលទើបកើតថ្មីមិនព្រមចប់ អ្វីត្បិតតែព្រះអង្គ សៅ ឃន ឈប់ជាចៅអធិការវត្តមុនហើយក៏ដោយ? ហើយមានការសង្ស័យថា **តទៅទំព័រទី១៣**

## តមកពីទំព័រទី ១២ វត្តខ្មែរឡូវែលឆ្លើយតបការចោទប្រកាន់...

អ្នកស្រី ម៉ាយ៉ា ម៉ែន ទិញផ្ទះដោយសារលុយវត្តខ្មែរថែមទៀត ?

**អ្នកស្រីម៉ាយា ម៉ែន :** អ្នកចោទខ្ញុំនោះគ្រាន់តែជាការស្មានមានភស្តុតាងទេ ថាខ្ញុំយក



លុយវត្ត? នាងខ្ញុំជាសកម្មជនបំរើពុទ្ធសាសនាដោយស្ម័គ្រចិត្ត គួរណាស់តែទទួលបាននូវការលើកទឹកចិត្ត បែរជាមកបំផ្លាញខ្ញុំ ក៏ដូចជាបំផ្លាញទឹកចិត្តអ្នកបានមកបំរើវត្តទាំងអស់ខ្ញុំមិនអាចទទួលយកបានទេ ត្រូវតែរកយុត្តិធម៌ជូនសប្បុរសជនបំរើវត្ត ចូលរួមជួយវត្តទាំងអស់មកវិញ ។ កាលពីខែសីហា លោក មាស សែម បានលើកគ្នា៥-៦នាក់មកឡូឡាតវ៉ាទាមទារធ្វើ"អឌិត" គណនេយ្យវត្តខ្មែរឡូវែល ដោយគ្មានឱ្យដំណឹងជាមុន មានការមើលងាយព្រះសង្ឃមិនសមជាអ្នកកាន់ព្រះពុទ្ធសាសនាទេ -ចំពោះរឿងលុយនេះ ខ្ញុំមិនអាចនិយាយអ្វីបានទេ នាពេលនេះមុនពេលឡើងតុលាការ ។

**ព្រះអង្គ ញ៉ែម គិមតេង :** យើងឥតមានលុយ៥ម៉ឺន ឬ១០ម៉ឺនឯណាសម្រាប់អ្នកស្រី ម៉ែន ម៉ាណា យកទៅទិញផ្ទះនោះទេ ប្រសិនបើមានក៏មិនអាចស៊ីញ៉េសែកទៅឱ្យបានដែរ ពីព្រោះវាខុសនឹងគោលបំណងនៃសប្បុរសជនដែលគេឱ្យមកកសាងវត្តយើងជាព្រះសង្ឃដែលបានបួស២០-៣០-៤០ឆ្នាំរួចមកហើយ បានបូជាជីវិតដើម្បីសាសនារួចហើយ មិនអាចក្បត់នឹងពុទ្ធបរិស័ទរាប់ពាន់នាក់ដែលផ្ញើសេចក្ដីទុកចិត្តលើយើងនោះទេ "សែក"មួយដែលយើងស៊ីញ៉េទៅឱ្យលោកវិឆឹត បយ គឺវាមានបំណងរបស់វា គឺសងថ្លៃដី ឬសងថ្លៃមេធាវីការពារផលប្រយោជន៍សំណងរបស់វត្ត ចុះបើយើងឱ្យទៅឈ្មោះផ្សេងណាម្នាក់វានឹងមានបំណងផ្សេងគេអាចដឹងគ្រប់គ្នា មិនអាចធ្វើទៅបានទេ។ អាត្មាគិតថា រឿងរ៉ាវកើតមិនចេះចប់នេះ គឺជាជំងឺឆ្លង មើលពីចិត្តសាស្ត្របន្តិចទៅយើងឃើញថា សង្គ្រាមនៅកម្ពុជានា៣០-៤០ឆ្នាំកន្លងទៅនេះ វាធ្វើឱ្យយើងប្រែប្រួលមិននឹងហ្ន៎ កើតជំងឺសង្ស័យ ជំងឺមិនទុកចិត្តឆ្លងពីមួយទៅមួយអាហ្នឹងជាជំងឺផ្លូវចិត្តមួយហើយពរ... បើឱ្យជ្រៅជាងនេះបន្តិចទៅទៀត គឺចរិតដែលលោក ប៊ុន ចាន់ម៉ុល សរសេរពី"ចរិតខ្មែរ" អាត្មាបានអានហើយអន់ចិត្តនាពេលនោះ តែឥឡូវធ្វើការក្នុងសង្គមច្រើនទៅទើបយល់ថា លោក ប៊ុន ចាន់ម៉ុល សរសេរមិនទាន់គ្រប់គ្រាន់នៅឡើយទេ -ម្លោះហើយចំណុចវាយលើព្រះសង្ឃបានលើសាសនាបានមានតែ២ទេ គឺទី១ : លុយកាក់សហគមន៍សង្ឃនេះធ្វើការលឿន តែ១ឆ្នាំសោះបោះជំហ៊ានលឿនហួសការស្មាន -ទីពីរស្រ្តីៈដែលធ្វើឱ្យកិត្តិយសព្រះសង្ឃល្អក់កករ ដែលយើងមិន



វត្តសហគមន៍ព្រះសង្ឃខ្មែរ និងវត្តខ្មែរឡូវែលសព្វថ្ងៃ

បានស្រាវជ្រាវថា គេធ្វើនេះដើម្បីអ្វីនៅឡើយទេពុទ្ធសាសនិក ឬក៏មិនមែនក៏យើងមិនដឹង ។

**សំនួរខ្មែរផុស :** ចំពោះរឿងស្រ្តីមានការសង្ស័យពេលមុនៗថា ព្រះតេជគុណ សៅ ឃន មានរឿងផ្លូវចិត្តសំងាត់ជាមួយអ្នកស្រី ម៉ាយាម៉ែន តើព្រះអង្គឆ្លើយតបយ៉ាងណា?

**ព្រះអង្គ សៅ ឃន :** អាចប្រកាសបានថានេះជារឿងផ្សាយក្នុងកាសែតឡូសាន់ដែរថា អាត្មាលួចលុយ៥ម៉ឺនពីវត្តត្រៃរតនារាមមកទិញដីថ្មីភស្តុតាងថា លុយបានពីណាមានទាំងអស់ខ្ចីពីវត្តលីន ខ្ចីពីអ្នកស្រុកបូកនឹងលុយមានខ្លះ បានលុយទៅយកដីនោះ -ចំណែកឯរឿងជាមួយអ្នកស្រី ម៉ាយ៉ា ដូចគ្នាដែរ ឃើញ ម៉ាយ៉ា ជាមនុស្សសកម្មពូកែប្រមូលពុទ្ធសាសនិកមកធ្វើបុណ្យ ដើម្បីគាំទ្របើបានមនុស្សដូចគាត់តែ៤នាក់ទៅការងារនោះរត់ល្អតែម្ដង ដោយសារតែ ម៉ាយ៉ា ជាមនុស្សពូកែនេះហើយ ទើបគេវាយប្រហារអាត្មានឹងរឿងស្រ្តីនេះឯង ហើយនេះមិនមែនជារឿងថ្មីទេ...

**ព្រះអង្គ ញ៉ែម គិមតេង :** តាំងពីជំនាន់ព្រះក៏មានរឿងស្រ្តីហ្នឹងដែរ ដោយសារពួកនិគ្រតដេរថី ចង់ផ្ចាញ់ព្រះសម្មាសម្ពុទ្ធបាន ទៅចាប់នាងចិញ្ចា ជួលឱ្យនាងនោះសំដែងជាស្រ្តីមានផ្ទៃពោះទៅចង្អុលមុខព្រះពុទ្ធចោទប្រកាន់ព្រះអង្គដែលកំពុងសម្ដែងធម៌ទេសនា ចំពោះមុខពុទ្ធសាសនិកជាច្រើនបង្អាប់កិត្តិយសព្រះអង្គ ថាកូនក្នុងពោះនាងជាបុត្ររបស់ព្រះអង្គ ប៉ុន្តែអំណាចព្រះពុទ្ធព្រះឥន្ទាធិរាជក្រឡាខ្លួនជាសត្វកណ្ដុរទៅកាត់ចំណងចងនៅពោះនាងចិញ្ចាធ្វើឱ្យធ្លាក់ដុំឈើមកដី ក៏លេចការពិតភ្លាមឱ្យគេឃើញ ។ ចំណែកឯអាត្មាព្រះតេជគុណ សៅ ឃន ក្ដីយើងជាមនុស្សបថុជនមានបារមីពីណាធ្វើឱ្យគេឃើញភ្លាមៗបាន នាងចិញ្ចាកាន់សាសនានិគ្រតតេរថីមកផ្ចាញ់ព្រះពុទ្ធនេះនៅគ្រាន់បើបន្តិច ចំណែកឯខ្មែរយើងនេះថា ខ្លួនកាន់ព្រះពុទ្ធសាសនា ហើយផ្ចាញ់ព្រះសង្ឃនូវរឿងអកុសលអ្វីផ្សេងៗអាហ្នឹងអន់ណាស់...

**ព្រះតេជគុណ សៅ ឃន :** ទាក់ទងនឹងរឿង ម៉ាយា ជាមួយអាត្មានេះ សូមបញ្ជាក់ថា អាត្មាត្រូវគេប្ដឹងជិតងាប់ហើយ ដោយនៅជិតអាត្មាសុទ្ធតែមនុស្សល្ងង់ បានជួប ម៉ាយានេះ ជាមនុស្សឆ្លាត រកកាដោះស្រាយដោយការប្រជុំក្រុមអ្នកចេះ២-៣ដងក៏ដោះស្រាយរួចបន្តបន្ទាប់ -នៅរ៉ូដអាយឡិនឯណោះសោះប្រមូលអ្នកនៅឡូវែលមកធ្វើបុណ្យផ្កាបាន២ម៉ឺនមកធ្វើជណ្ដើរវត្តត្រៃរតនារាម ធ្វើឃឿនខាងមុខអស់១ម៉ឺនដែរ -ក្រោយមកទៅសោតការ៉ូឡាណាធ្វើស្តូបជ័យវ៉ូនទី៧អស់១០ម៉ឺន ធ្វើបុណ្យអស់៥ម៉ឺន អ្នកខ្លះថា "ងាប់ហើយជឿ ម៉ាយា រលំហើយ"ម៉ាយ៉ាអធិដ្ឋានថា "សុំឱ្យព្រះពុទ្ធសាសនារុងរឿងនៅសោតការ៉ូឡាណា"ធ្វើបុណ្យចប់រកបច្ច័យបានគ្រប់សងគេហើយនៅសល់ខ្លះទៀត -ក្រោយបន្ទាប់មកទៀតប្រជុំសង្ឃនៅហ្វីឡាគេថា "សុំឱ្យចេញពីវត្តចាស់នោះទៅរកដីថ្មីសង់វត្តសហគមន៍ព្រះសង្ឃខ្មែរ" ម៉ាយា មកវិញ ស្វះស្វែងរកតាមលោក វិទ្ធី តាមលោក ដេវីដ ខ្លះ អាត្មាឥត ដឹងរឿងអីទេ នៅទីបំផុតមកបានទីនេះមែន! គឺម៉ាយាជាអ្នកប្រមូលមនុស្សរហូតមកអ្នកឯទៀតគ្មានគំនិតប្រមូលផ្ដុំអីទេ... ដូច្នេះហើយមានការភ័យខ្លាច ហើយក្លាយជាសង្ស័យដោយដំណើរ ការវាលឿនពេក... ម៉ាយា បានចូលទៅជួយ ពេលក្រោយទៀតក្នុងការបោះឆ្នោតឃោសនាឱ្យលោក មាស សែម រឹង មាស សែម បែរជាមកចូលគណកម្មការកសាងវត្ត ដើម្បីទារកាន់លុយ និងប្តូរហត្ថលេខាឱ្យខ្លួនដែលអាត្មាធ្វើឱ្យមិនបានទេ។ ឃើញយើងនឹងមានសមាជិក៨ម៉ឺន៤ពាន់នាក់ ឃើញកាន់ប្រាក់លានចង់គ្រប់គ្រង រឹងអ្នកព្រួយបារម្ភ គឺព្រះសង្ឃ សុផុន ព្រះអង្គ ហុក សាវ៉ាន់ ព្រះអង្គ គិមតេង ដែលត្រូវសងគេរាប់លានដុល្លារនោះមានដែលមានលុយលានពីណា? ដូច្នេះសេចក្ដីសង្ស័យនេះ ហើយដែលជាគោលការណ៍ធ្វើអ្វីមិនបានសម្រេចអាត្មាជួយវត្តលាវជួយវត្តសៀមបានសម្រេច ឥឡូវមិនសូវហ៊ានទៅទេ ព្រោះខ្មាស់គេខ្មែរធ្វើអ្វីត្រង់ណាបែកបាក់ត្រង់ហ្នឹង... ហេតុនេះហើយត្រូវធ្វើការបង្រួបបង្រួមព្រះសង្ឃជាមុន ដើម្បីឱ្យសាសនាព្រះពុទ្ធសង្គ្រោះគ្រួសារខ្មែរជាបន្តទៅទៀត ។

**ព្រះអង្គ សាវ៉ាន់ ហុក ហៅលោកតាសៀមរាបៈ** អាត្មាពេញចិត្តនឹងជួយជ្រោមជ្រែង



ឱ្យបានសម្រេច តែថ្មីៗនេះមានការខកចិត្តច្រើនដែរ តែនៅតែប្ដេជ្ញាចិត្តថា នឹងបន្តដំណើរទៅមុខទៀតជាមួយព្រះតេជគុណ សៅ ឃន មិនឈប់ទេ ។ អាត្មាត្រូវគេនិមន្តឱ្យទៅជួយគង់នៅវត្តត្រៃរតនារាមវត្តខាងលើគណកម្មាធិការមាន១២រូប គឺ៦រូបខាងក្រោម និង៦រូបខាងលើ ។

**ព្រះតេជគុណ សៅ ឃន :** អាត្មាប្រគល់វត្តឱ្យគណកម្មាធិការនៅខែកញ្ញា២០១០អាត្មាលះបង់អស់ហើយ តែគេនៅតែចោទថា ព្រះសង្ឃជាអ្នកនាំអាទិ៍តែគណកម្មការចែកជាពីរចូលរួមគ្នាមិនចុះសម្រុងគ្នាទេ ។

**ខ្មែរផុស :** ខ្ញុំព្រះករុណាសូមអរព្រះគុណ និងអរគុណចំពោះការផ្ដល់បទសម្ភាសន៍នេះ ៕







# មណ្ឌលសង្គ្រោះដំរី នៅភ្នំគូលែន




កាលវ័យ៥ឆ្នាំកុមារីសាំង ឌឿន ឡឺក ឆាយឡឺត បានរស់នៅឯភូមិដ្ឋានកុលសម្ព័ន្ធមួយ ភាគខាងជើងនៃប្រទេសថៃជាមួយជីតារបស់នាង ដែលជាគ្រូមើលជំងឺតម្កាត់ផ្សេងៗ។ គ្រួសាររបស់នាងត្រូវបានអ្នកជំងឺម្នាក់ជូនសត្វដំរីជាអំណោយតបស្នងនឹងការព្យាបាលរោគាឱ្យជះសះស្បើយ។ ឡឺក និងសត្វដំរីនោះគឺជាមិត្តសម្លាញ់នឹងគ្នា ហើយមនោសញ្ចេតនានេះបានធ្វើឱ្យឡឺកមានក្តីប្រាថ្នាចង់ធ្វើកិច្ចការលើកកម្ពស់ជីវិតសត្វដំរីនានាទាំងក្នុងស្រុក និងក្នុងព្រៃ ។ ៤០ឆ្នាំកន្លងមក ឡឺក បានមកបង្កើតសហគមន៍សត្វដំរីថ្មីដ៏ធំមួយឈ្មោះថា មណ្ឌលសង្គ្រោះសត្វដំរីកម្ពុជាឋិតស្ថិតនៅតំបន់ឧទ្យានជាតិភ្នំគូលែន ចម្ងាយប្រមាណជា១ម៉ោងដោយធ្វើដំណើរតាមរថយន្តពីទីរួមខេត្តសៀមរាប ។មណ្ឌលនេះគឺជាបណ្តាញមួយរបស់អង្គការសង្គ្រោះសត្វព្រៃកម្ពុជា ហើយ វានឹងត្រូវបានគេបើកឱ្យសាធារណជនចូលទស្សនានៅចុងឆ្នាំនេះផងដែរ ។ មណ្ឌលទើបតែទទួលបានសមាជិកថ្មីដំបូងនៅឆ្នាំនេះដោយបានសង្គ្រោះដំរីញីពីរក្បាលកាលពីថ្ងៃទី១៦ ខែមករាកន្លងមក ។ ម្ចាស់វាបានដាក់ទូកធ្វើដំណើរចេញពីខេត្តរតនគិរីតាមទន្លេមេគង្គដោយចំណាយពេល១៦ម៉ោងឯណោះ ទើបដល់មណ្ឌលសង្គ្រោះខេត្តសៀមរាប ។ មណ្ឌលសង្គ្រោះសត្វដំរីកម្ពុជាដែលគ្រោងនឹងស្វាគមន៍ដំរី១០ក្បាលនៅឆ្នាំដំបូងនេះមានក្រុមការងារចំនួន៤០នាក់ធ្វើកិច្ចការលើផ្ទៃដីព្រៃឈើចំនួន២,៥ ហិកតានោះ ក៏កំពុងតែត្រូវការអ្នកស្ម័គ្រចិត្តសម្រាប់កិច្ចការនៅក្នុងមណ្ឌល ដូចជាខាងថែទាំព្រៃឈើ និងគ្រប់គ្រងដីធ្លីជម្រកសត្វ និងអ្នកថែទាំសត្វដំរី។ អ្នកនាង ឡឺក ជាស្ថាបនិកមណ្ឌលសង្គ្រោះសត្វដំរីកម្ពុជាបាននិយាយថា គម្រោងនេះមានគោលបំណងចង់ផ្សារភ្ជាប់សត្វដំរីទៅនឹងជីវិតក្នុងព្រៃ ក៏ដូចជាអប់រំប្រជាជននៅក្បែរនោះឱ្យបានយល់ដឹងពីការការពារសត្វព្រៃ និងរុក្ខជាតិ ។ ស្ថាបនិករូបនេះថ្លែងថា : មណ្ឌលយើងមិនត្រឹមតែមានគោលដៅជួយរក្សាសត្វព្រៃ និងសង្គ្រោះដំរីមុននឹងលែងពួកវាឱ្យទៅរស់នៅក្នុងព្រៃវិញនោះទេ ប៉ុន្តែយើងក៏ធ្វើកិច្ចការជាមួយប្រជាជនក្នុងសហគមន៍ផងដែរ ។ គួរបញ្ជាក់ថា អ្នកនាង ឡឺក ក៏ទទួលបានកិត្តិយសល្បីរន្ទឺសម្រាប់ស្នាដៃជួយអភិរក្សជីវិតសត្វដំរីនៅអាស៊ីដែរ តាមរយៈការលេចមុខក្នុងខ្សែភាពយន្តឯកសាររបស់បណ្តាញទូរទស្សន៍ប៊ីប៊ីស៊ី ប៉ុស្តិ៍ National Geographic និង Animal Planet ។ ឆ្នាំ២០០៥ នាងត្រូវបានទស្សនាវដ្តីឈ្មោះ ថាសម៍ ផ្តល់ងារថា វីរនារីអាស៊ីសម្រាប់កិច្ចការអភិរក្សសត្វព្រៃ។ ឆ្នាំ២០១០ អ្នកនាង ឡឺក ក៏ទទួលបានការអញ្ជើញពីលោកស្រីហ៊ីលឡារី គ្លីនតុន ទៅទស្សនកិច្ចនៅក្រុង វ៉ាស៊ីនតោន ដើម្បីទទួលងារជាវីរនារីឆ្នើមខាងអភិរក្សថ្នាក់សកល ៕



## តមកទំព័រទី ៩ អ្នកក្រ និងអ្នកមាននៅប្រទេសខ្មែរ...

តមកទំព័រទី ៩

អ្នកមានខ្មែរដឹងខ្លួនទេថាខ្លួនមានលុយច្រើនមានមាសពេជ្រ មានសំលៀកបំពាក់ល្អលើសពីគេឯងមានឡានទំនើបជិះដំឡៃរាប់ម៉ឺនដុល្លាសហរដ្ឋអាមេរិក ទៅណាមកណាត្រូវមានអង្គរក្សតាមការពារ? អ្នកមានខ្មែរដឹងទេថា រាល់ថ្ងៃខ្មែររាប់រយនាក់ចេញតាមច្បាប់ឬមិនតាមច្បាប់ពីស្រុកខ្មែរទៅធ្វើជាកម្មករនៅក្រៅស្រុក? អ្នកមានខ្មែរដឹងទេថាខ្មែរស្ទើរតែរាល់ស្លាប់តាមផ្លូវចូលខុសច្បាប់ដល់ដីថៃ? អ្នកមានខ្មែរដឹងទេថា កម្មកររោងចក្រនៅស្រុកខ្មែររាប់សែននាក់បានប្រាក់ខែមិនគ្រប់គ្រាន់គាំទ្រជីវិត ហើយបន្ថែមលើនោះ មានខ្លះដួលសន្លប់នៅពេលធ្វើការស្ទើរតែរាល់ថ្ងៃ? អ្នកមានខ្មែរដឹងទេថា ខ្មែរនៅស្រុកខ្មែរយ៉ាងតិច៨០ភាគរយវេទនាណាស់? អ្នកមានខ្មែរដឹងទេថាមានខ្លះបង់ឱ្យមានព្រឹត្តិការណ៍នៅស្រុកខ្មែរ ដូចព្រឹត្តិការណ៍នៅខែមេសាឆ្នាំ៧៥? ទាំងអស់គ្នាចាំទេថា ព្រឹត្តិការណ៍នៅដើមខែកក្កដាឆ្នាំ១៩៩៧បណ្តាលឱ្យមានការខូចខាតយ៉ាងច្រើន ទាំងសម្បត្តិទ្រព្យទាំងជីវិតមនុស្ស? អ្នកជំនួញម៉ូតូនៅអូរឫស្សីម្នាក់សម្លាប់ខ្លួនឯងដោយសារការបាត់បង់ទ្រព្យសម្បត្តិ។ យើងទាំងអស់គ្នាដឹងថា សេចក្តីក្រអត់ឃ្លានធ្វើឱ្យមនិស្សភ្លេចសិលធម៌ភ្លេចគ្រោះថ្នាក់ដល់ខ្លួន ភ្លេចដល់សេចក្តីស្លាប់ទៀតផង។

តាមការសង្កេតរបស់ខ្ញុំ អ្នកមានខ្មែរអាចជួយធ្វើឱ្យស្រុកខ្មែរនិងប្រជាពលរដ្ឋចម្រើនទៅមុខបាន គឺអាចជាគន្លឹះជួយធ្វើឱ្យស្រុកខ្មែរ និងប្រជាពលរដ្ឋខ្មែរចាកផុតពីគ្រោះមហន្តរាយបាន។

តើរាជរដ្ឋាភិបាលនិងធនាគារអាចជួយអ្នកមានតាមរបៀបណាដើម្បីឱ្យអ្នកមានសម្រេចគោលបំណងនេះបានខ្ញុំសុំជូននៅពេលក្រោយ ៕

***គិម សុស់ មន្ត្រីក្រសួងការបរទេស ចូលនិវត្តន៍**










តមកពីទំព័រទី ១

# រដ្ឋកាលបន្ទាប់ពីសីហនុ

កម្ពុជាជាយុទ្ធជនជួរមុខ ដើម្បីធ្វើសង្គ្រាមត្រជាក់ បោះជំហានទៅប្រទេសអាស៊ីឯទៀតៗ ដែលនៅសល់បន្ទាប់ពីវៀតណាម ឡាវ ក៏ប៉ុន្តែដំណើរនេះនៅមានភាពរអាក់រអួល ដោយមិត្តភាពចិន-វៀតណាម កំពុងស្ថិតនៅលើអត្ថប្រយោជន៍តែរៀងៗខ្លួននៅឡើយ ពុំមែនដោយសារមនោគមន៍វិជ្ជា ឬវប្បធម៌ជាបងប្អូននោះទេ ទាំងនេះជាសញ្ញានៃ"ភ្នំភ្លើងដេក" ទី១ **២-គ្មានលំនឹងគ្រប់គ្រងផ្ទៃក្នុង :**

រីឯសញ្ញាបន្ទាប់ គឺឥទ្ធិពលនៃអំណាចគ្រប់គ្រងរដ្ឋនៅកម្ពុជា ។ ព្រះរាជណាចក្រកម្ពុជាគ្រប់គ្រងដោយព្រះមហាក្សត្រថ្មីនរោត្តម សីហមុនី តែស្តេចអង្គនេះ ពុំមានអំណាចគ្រប់គ្រងកម្ពុជាដូចដែលរដ្ឋធម្មនុញ្ញបានចែងជាផ្លូវការនោះទេ បន្ថែមពីលើនេះទៀត ព្រះអង្គបានបង្ហាញព្រះទ័យថាមិនចង់គង់ជាស្តេចសោយរាជ្យថែមទៀត ។ អំណាចទាំងមូលបានធ្លាក់ទៅលើដៃនាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលពេលនេះ ជាទីទំនុកចិត្តរបស់ចិន របស់វៀតណាម និងរបស់បក្សកុម្មុយនីស្តប្រជាជនកម្ពុជាតាំងពី៣០ឆ្នាំមកហើយ ក៏ប៉ុន្តែលោកនាយករដ្ឋមន្ត្រីរូបនេះពុំបានដើរតាមមាគ៌ានៃអ្នកដែលឱ្យសេចក្តីទុកចិត្តដល់ខ្លួននោះទេ លោកបានបង្កើតអាណាចក្រថ្មីមួយទៀត តាមគំរូកូរ៉េខាងជើងរបស់លោក គីម អ៊ីលស៊ុង គឺអំណាចតពូជសម្រាប់ក្រុមគ្រួសារផ្ទាល់របស់លោក និងបរិវារតែប៉ុណ្ណោះ ។ នេះជាសញ្ញានៃ"ភ្នំភ្លើងដេក"ទី២ ដែលសម្ព័ន្ធមិត្តផ្ទៃក្នុងរបស់ខ្លួនត្រៀមរកឱកាសល្អសម្រាប់ប្តូរដៃ ហើយក៏ជាឱកាសល្អសម្រាប់ក្រុមទី៣ផ្សេងទៀត រំដោះកម្ពុជាចេញពីនឹមកុម្មុយនីស្តផងដែរ ។

**៣-លំនឹងនៃសេដ្ឋកិច្ចគ្រួសារខ្មែរ**

ខ្មែរជាច្រើនមានការកោតសរសើរពីសោភ័ណភាពថ្មីនៃការរីកចំរើននៅស្រុកខ្មែរ ក៏ប៉ុន្តែសេចក្តីរាយការណ៍សាធារណបានបង្ហាញថា "អ្នកមាន"កាន់តែមានទៅ រីឯចំនួនក៏កាន់តែតិចទៅ ចំណែកឯ"អ្នកក្រ"កាន់តែក្រទៅ ហើយចំនួនក៏កាន់តែច្រើនឡើង (**សូមអានអត្ថបទអ្នកក្រអ្នកមានរបស់លោក គឹម សុស**) ។ ការបាត់លំនឹងក្រនៅក្នុងស្រទាប់សង្គមមនុស្សអាចបណ្តាលឱ្យមានកលយុគធំៗក្នុងប្រទេស ដូចដែលប្រវត្តិសាស្ត្របានបង្ហាញស្រាប់ ។ បន្ថែមពីលើលំនឹងនេះនៅមានអំពើពុករលួយនៅក្នុងបណ្តាអ្នកកាន់អំណាចអ្នកកាន់អាវុធអំពើធ្វើបាបទារុណកម្មប្រកបដោយភាពអយុត្តិធម៌អំពើបំបាត់សិទ្ធអ្នកដីទៃសុទ្ធសឹងតែជាប្រភពនៃការរើបំរះគ្មានស្តាយជីវិតនៃអ្នករងគ្រោះទាំងអស់ ។ នេះជា"ភ្នំភ្លើងដេក"ទី៣ ដែលឧទាហរណ៍ជាក់ស្តែងបានរំលំរដ្ឋអំណាចផ្តាច់ការដោយកម្លាំងប្រមូលផ្តុំនៃពលរដ្ឋរងគ្រោះបានច្រើនរបបរួចមកហើយ នាជុំវិញពិភពលោកប្រមាណតិចជាង១០ឆ្នាំចុងក្រោយនេះ ។

**អ្វីខ្លះដែលកំពុងកើតឡើងនៅកម្ពុជា**

**១-ជាក់ស្តែង :** កម្ពុជាបាត់បង់នូវភាពឯករាជ្យក្នុងការសម្រេចវាសនាជាតិដោយខ្លួនឯង ផលប្រយោជន៍ទាំងអស់របស់ជាតិហូរទៅវៀតណាម និងចិន ។

-កម្ពុជាបន្ទាប់ពីរដ្ឋាភិបាល -សភាជាតិ និងព្រះមហាក្សត្រចុះហត្ថលេខាលើផែនទីថ្មី ពុំមាននរណាដឹងច្បាស់លាស់ថា ដីខ្មែរសល់ប៉ុណ្ណានោះទេ តែភាពច្បាស់លាស់ គឺបង្គោលសីមាថ្មីនៃព្រំប្រទល់ខ្មែរ-វៀតណាម បោះចូលមកក្នុងភូមិខ្មែរ ច្រើនកន្លែងរួចហើយ ជាសញ្ញាថា ខ្មែរបាត់បង់ដីខ្លួនខ្លះហើយ ។

**២-ភាពស្មុគ :** -អំពើពុករលួយ បក្សពួកនិយម លះបង់សីលធម៌ គឺជាទង្វើសាធារណ និងផ្លូវការដែលពុំមានអង្គការណាដាក់ទោសបានឡើយ -ប្រជាជាតិទាំងមូលត្រូវសម្របទៅតាមទស្សនៈថ្មីនេះ ដើម្បីរក្សាជីវិត ។

-អ្នកក្រីក្រ -អ្នកមានចំណេះតិច គ្មានទទួលការបីបាច់ថែរក្សា គ្មានការជួយបង្កើតសំណាងឱ្យអាចរស់ដោយខ្លួនឯងបានគ្មានការលើកទឹកចិត្តឱ្យទទួលការអប់រំត្រឹមត្រូវខូចខាតសុខភាពរាងកាយ នឹងប្រាជ្ញាតាំងពីតូច ។

-កុមារ -យុវជន មនុស្សជំនាន់ក្រោយកំពុងទទួលភាពជាក់ស្តែង និងភាពស៊ីរូងដែលភ្នែកមើលមិនឃើញតែផ្តល់នូវក្តីវិនាសទៅអនាគតថា នេះជាវាសនា ហើយទទួលយកថា នេះជាវប្បធម៌របស់ខ្មែរទូទៅ ។

**៣-ភាពរើបំរះ :** គណបក្សប្រឆាំងនៅកម្ពុជាស្ថិតនៅជួរមុខគេបង្អស់ដែលខិតខំធ្វើសកម្មភាពបង្ហាញពីភាពគ្រោះថ្នាក់ដល់ប្រជាជាតិដល់ពលរដ្ឋដល់ជំនាន់ក្រោយ ។ បក្សនោះមានការគាំទ្រពីសហគមន៍ខ្មែរ នៅក្រៅប្រទេសយ៉ាងច្រើន និងយ៉ាងចេញមុខនៅក្នុងប្រទេស ក៏មានច្រើនតែច្រើនលាក់មុខមានការគាំទ្រពីប្រទេសសេរីតែពុំមានជំនួយទេ ។

-បក្សប្រឆាំង និងរដ្ឋាភិបាលមួយចំនួនទៀតមានសារជាតិជាមនុស្សសេរីតែមិនច្បាស់លាស់ពីការគោរពសីលធម៌បានត្រូវមនុស្សខាងរដ្ឋាភិបាលប្រើប្រាស់ដោយចំពោះ ឬដោយប្រយោលដើម្បីបំបែកសាមគ្គីភាពនៃក្រុមអ្នកប្រឆាំង ។

-បក្សរាជានិយមគ្មានសារជាតិជាកុម្មុយនិស្តទេ ជាមនុស្សសេរីសម្បូរអ្នកចេះ តែត្រូវចូលរួមអំណាច ដើម្បីរង់ចាំឱកាសល្អ ដើម្បីយកអំណាចមកវិញ តែព្រះមហាក្សត្រខ្លួនពុំមានបំណងនេះទេ ។ ក្រុមនេះមានការទ្រទ្រង់ពីអំណាចរដ្ឋដែលរដ្ឋអំណាចគេធ្វើសម្បទារសម្រាប់ជួយកែលំអរមុខមាត់របស់គេ ហើយនៅពេលគេឈររឹងមាំហើយអាចនឹងទាត់ចោលរាជានិយមវិញបាន ។

-ក្រុមអ្នកមានអំណាចជាបក្សប្រជាជនកម្ពុជា បានចែកជាពីរប្រភេទ -ប្រភេទទី១ គឺក្រុមបច្ចុប្បន្ននាយករដ្ឋមន្ត្រីដែលក្តោបអំណាចយ៉ាងមាំតាំងពី៣០ឆ្នាំមកហើយ និងក្រុមទីពីរនៃលោកប្រធានបក្ស ជា ស៊ីម ពីរជាង២០ឆ្នាំមកហើយដែរ ។ ក្រុមទី២នេះ ចង់កាន់អំណាចកំពូលរបស់ប្រជាជាតិដែរ តែឡើងមិនរួចដោយអំណាច និងការគាំទ្ររបស់ក្រុមលោកនាយករដ្ឋមន្ត្រីមានទំហំខ្លាំងក្លាហើយទាយទុកមុនមិនបាន -ក្រុមទី២នេះ គ្រប់គ្រងអំណាច **តទៅទំព័រទី ១៧**



ខេត្តក្រុង និងរដ្ឋបាលច្រើនកន្លែងស្មើ ឬច្រើនជាងក្រុមទី១ តែពុំមានអំណាចដាច់ណាក់នោះទេ -ក្រុមទី២ នេះក៏រង់ចាំឱកាសសំរាប់ដណ្តើមអំណាចដែរ ។

**ភាពបដិបក្សនៃប្រទេសជិតខាង**

ប្រទេសចិនចង់ឈរជាមគ្គុទេសកុម្មុយនិស្ដជំនួសរុស្សីដែលបានរំលំដួលជាបំណែកតូចៗ -ឥឡូវរកស៊ីមានលុយច្រើនចង់បន្តរពង្រីកអាណាចក្ររបស់ខ្លួនជាឥទ្ធិពលកុម្មុយនីស្ដបែបចិនទៅលើពិភពលោក តែមិនបញ្ចេញមុខច្បាស់ប្រើសង្គ្រាមត្រជាក់ ពីព្រោះបច្ចេកវិជ្ជា និងកម្លាំងទាក់ទាញមិនស្មើទស្សនៈសេរីនៃបច្ចឹមប្រទេស ។

**ប្រទេសវៀតណាម :** រួបរួមខាងជើង និងខាងត្បូងបានដោយសារពួកលោកខាងលិចដកថយ យល់ព្រមឱ្យចិនប្រើឥទ្ធិពលខ្លួនក្នុងតំបន់យល់ព្រមឱ្យចិនចូលផ្សារសេរី ចិនអាចការពារវៀតណាមកុម្មុយនីស្ដបាន តែវៀតណាមយកកម្លាំងការពារនេះ ទៅរំលោភទឹកដីខ្មែរ និងឡាវ ។ ២០ឆ្នាំក្រោយមករវល់តែរឿងយកដីគេវៀតណាមឥឡូវកំពុងប្រឈមមុខ និងវិបត្តិនៃការទុកចិត្ត គ្មានវិនិយោគ គ្មានអ្នកចូលបណ្តាក់ទុន ហើយមានវិបត្តិសេដ្ឋកិច្ចធ្វើឱ្យរាស្ត្រវៀតណាមមិនសប្បាយចិត្ត ។

**ប្រទេសសៀម :** នៅជារនាំងទប់ទល់ដំណើរទៅមុខនៃបក្សកុម្មុយនីស្ដចិន -វៀតណាមឡាវ រីឯកម្ពុជាដែលមាន អ.ស.ប នៅទីនោះក៏ក្លាយទៅជាសមរភូមិជួរមុខនៃការប្រទាញប្រទង់រវាងបក្សសេរី និងកុម្មុយនិស្ដទីនោះដែរ ។

**សូមរង់ចាំអានភាគបន្តនៅលេខក្រោយ**

# ព្រះនរោត្តម ស៊ីហនុ
## ប្រវត្តិ (១៩២២-២០១២)

**ដោយ : សាគូ សាមុត**

ព្រះអង្គម្ចាស់នរោត្តមសីហនុ ប្រសូត្រនៅថ្ងៃអង្គារ៍ ទី៣១ ខែតុលា ឆ្នាំ១៩២២ នៅរាជធានីភ្នំពេញ ។ ព្រះបិតា សុរាម្រិត ព្រះមាតានាមកុសុមៈនារីរ័ត្ន ។

ពីឆ្នាំ១៩៣០ ដល់១៩៤០ ព្រះអង្គបានចូលសិក្សាសាលាបឋមសិក្សា FRANCOIS BAUDOIN និងវិទ្យាល័យស៊ីសុវត្ថិភ្នំពេញ បន្ទាប់មកព្រះអង្គបានបន្តការសិក្សានៅវិទ្យាល័យបារាំង CHASSELOUP LAUBAT នៅព្រៃនគរ ។

នៅឆ្នាំ១៩៤៦ និង១៩៤៨ ព្រះអង្គបានបន្តសិក្សាជាន់ខ្ពស់ផ្នែកយោធានៅសាលាអនុវត្តទ័ពសេះ និងកងទ័ពរថពាសដែកនៅ SAUMUR ស្រុកបារាំង ។

### ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា
### ការគ្រងរាជសម្បត្តិលើកទី១

នៅខែមេសា ឆ្នាំ១៩៤១ ក្រុមប្រឹក្សារាជបល្ល័ង្កបានជ្រើសតាំង និងថ្វាយព្រះរាជឋានៈព្រះអង្គជាព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជានៅរាជធានីភ្នំពេញ ។ ព្រះអង្គឡើងគ្រងរាជសម្បត្តិនៅថ្ងៃទី ២៨ ខែតុលា ឆ្នាំ ១៩៤១ ពេលនោះព្រះអង្គមានព្រះជន្ម១៩ឆ្នាំ ។ បន្ទាប់ពីប្រទេសកម្ពុជាបានឯករាជ្យពីបារាំងព្រះអង្គបានដាក់រាជ្យថ្វាយព្រះបិតា សុរាម្រិត នៅថ្ងៃទី២





ខែមិនា ឆ្នាំ១៩៥៥ ។

### ការគ្រងរាជ្យសម្បត្តិលើកទី២

បន្ទាប់ពីថ្វាយរាជ្យសម្បត្តិទៅព្រះបិតារួចព្រះអង្គបានចូលប្រឡូកក្នុងនយោបាយដោយបានបង្កើតគណបក្ស "**សង្គមរាស្ត្រនិយម**" ។ ជាដំបូងការគ្រប់គ្រងនយោបាយមានលក្ខណៈអព្យាក្រិត្យល្អប្រសើរ តែទីបញ្ចប់អព្យាក្រិត្យនេះចេះតែលំអៀងឆ្វេងទៅៗរហូតអនុញ្ញាតឱ្យកងកម្លាំងយួនកុម្មុនីស្ដ តាំងទីលើទឹកដីខ្មែរប៉ែកខាងកើតធ្វើសង្គ្រាមទៅយួនខាងត្បូងគាំទ្រ ដោយអាមេរិកប្លុកសេរី ។ នៅថ្ងៃទី១៨ ខែមិនា ១៩៧០ សភាទាំងពីរបានបោះឆ្នោតដកអំណាច "ប្រមុខរដ្ឋ" ពីសម្តេចសីហនុ ។ ប្រទេសកម្ពុជាបានឆ្លងកាត់សង្គ្រាមយ៉ាងធំដែលបញ្ចប់ដោយជ័យជំនះបានទៅកុម្មុយនីស្ដខ្មែរ-យួនដែលបណ្តាលឱ្យរាស្ត្រខ្មែរបាត់បង់ជីវិតជិត២លាននាក់ ។ ដំណោះស្រាយនយោបាយដោយមានការគាំទ្រពីអ.ស.ប អនុញ្ញាតឱ្យព្រះអង្គឡើងគ្រងរាជ្យលើកទី២ នៅថ្ងៃទី២៤ កញ្ញា១៩៩៣ រហូតដល់ថ្ងៃទី៧ ខែតុលា ឆ្នាំ ២០០៤ ។ ក្រោយពីការដាក់រាជ្យរួចព្រះអង្គបានត្រូវគេថ្វាយព្រះនាមថា "**ព្រះមហាវីរក្សត្រ**" ។ អ្នកស្នងរាជ្យបន្តមាននាមជា "**សីហមុនី**" ជារាជបុត្រព្រះអង្គ ។

### ព្រះរាជបូជនីយកិច្ច

ក្នុងរជ្ជកាលលើកទី១ កម្ពុជាស្ថិតនៅក្រោមអាណាព្យាបាលប្រទេសបារាំង ។ គ្រប់តែទំនាស់កម្ពុជា និងបរទេសសុទ្ធតែមានអន្តរាគមន៍ពីបារាំង ។ នៅឆ្នាំ១៩៤៧ ព្រះនរោត្តមសីហនុ បានទាមទារពីថៃឱ្យសងមកកម្ពុជាវិញ នូវខេត្តខ្មែរ ដែលថៃបានយកពីកម្ពុជានៅថ្ងៃទី៩ ឧសភា ១៩៤១ គឺខេត្តបាត់ដំបង,សៀមរាប, កំពង់ធំ, ស្ទឹងត្រែង។ នេះគឺបារាំងបានធ្វើការបើកផ្លូវជួយទាមទារឱ្យ ។ ឆ្នាំ១៩៤៩ព្រះអង្គបានទាមទារឱ្យបារាំងបញ្ឈប់នូវសន្ធិសញ្ញាអាណាព្យាបាលដែលបានចុះហត្ថលេខានៅឆ្នាំ១៨៦៣ និងឆ្នាំ១៨៨៤ ។ នៅឆ្នាំ១៩៤៩ដដែលព្រះអង្គបានឡាយព្រះអង្គបានឡាយព្រះហស្ថលេខាលើសន្ធិសញ្ញាឯករាជ្យដែលប្រទេសបារាំង **តទៅទំព័រទី ២២**


ANGKOR AUTO SERVICE,INC.
ហាងជួសជុលរថយន្ត "អង្គរ"
Free Estimate
Auto Body and Maintenance
BODY WORKS
Auto glass and windshields
Auto Frame Straightening and Painting



មានបទពិសោធន៏២០ឆ្នាំ ជាជាងរថយន្តមានសញ្ញាប័ត្រវាយតម្លៃការងារដោយឥតយកថ្លៃ ហើយយើងជួយសន្សំប្រាក់តម្លៃបន្ថយរបស់អិនស្វូរិនបានផង យើងផ្តល់សេវាគ្រប់យ៉ាង :

ENGINE AND TRANSIMISSION SERVICES
State Inspection
Check Engine Light Diagnostic
Timing Belt Services
Complete Tune Up:
-Brake -Muffler -Struts
-Water Pump -A/C
-Bearing Services



From the moment you get into car accident, we will take care of you from towing to calling your insurance, and to get a rental car for you. With Angkor Auto, you can be worried free.

4835 N. 16th Street. Philadelphia, PA 19141
Tel : (215) 455-7810 / Ricky : (215) 485-1425





Agent: Roeut Chak

PK Property, Inc.
ក្រុមហ៊ុនអចលនវត្ថុ លក់ ដូរ គ្រប់ប្រភេទ

ភីខេ ប្រភីធី (215) 635-5100
Roeut Chak - (267)872-3516
409 West Cheltenham Avenue
Melrose Park, PA 19027

**សម្រាប់បើកភោជនីយដ្ឋានខ្មែរ**
- 5706 N. 5th Street, Philadelphia PA 19120

ពីដើមជាភោជនីយដ្ឋាន ឥឡូវបិទ២០០០sqft បន្ទប់ដេកបី ជាន់ទី២ជា Apt គ្រឿងបរិក្ខាទាំងអស់នៅក្នុងផ្ទះឈ្នួល២០០០/ខែ

5734 N.2nd Street, Philadelphia, PA 19120
២៥០០ sqft ពីដើមជាភោជនីយដ្ឋាន មានកន្លែងចតឡាន៧៥- ឈ្នួល ២១០០/ខែ

**កន្លែងភ្លក់បៀរ BEER DELI**
- $16000/wk, Phila, Asking $99,000w/ Real Estate
- $13000wk, Phila., Asking $79,000w/ Real Estate
- $9000/wk, Asking $320.000
- $13,500/wk Asking $42000

**កន្លែងបោកគក់ដាក់កាត Co. Laundry**
- 100 Machines, 4500 sqft Asking $170,000
- $4500/wk Asking $200000
- 500/wk Bucks County; Asking $350,000

**កន្លែងចែកចាយបៀរ Beer Distributor**
- $1.3 Mil/yr, Bucks County, $250000 yearly income, Asking $1,150,000
- $75000/yr Philadelphia Asking $790,000 with RE
- 11,000,000 Philadelphia Asking $430,000

**សាឡុងធ្វើក្រចក Nail Salon**
- $18000/wk, Montgomery County, Asking $380,000
- $15000/wk South Jersey Asking $370,000

**សូមចូលទៅវេបសាយ**
www.pkpropertyinc.com to check more listings and office information.

# ប្រវត្តិរណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ
# រ.ជ.រ.ប.ខ លោកតា សឺន សាន

**ដោយ : ម៉ម យឺន**



ប៉ុន្តែគួរឱ្យមានការងឿងឆ្ងល់ចេញមកពីរឿង ដ៏ចំឡែកមួយនៅលើរូបលោកតា សឺនសាន ប្រធានរណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ។ គឺជារឿងកើតចេញមកពីលោកនាយករដ្ឋមន្ត្រីកម្ពុជាប្រជាមានិតលោក ហ៊ុន សែន នៅថ្ងៃលោកបានដឹងថា លោកប្រធាន សឺន សាន បានធ្វើដំណើរតាមអាកាសយានពីប្រទេសថៃចូលមកក្រុងភ្នំពេញលោក ហ៊ុន សែន បានបញ្ជាទៅកងនគរបាលវាលអាកាសយានដ្ឋានឱ្យត្រួតពិនិត្យរកច្បាប់អនុញ្ញាតឱ្យចូលប្រទេសកម្ពុជាជាមុនសិន បើគ្មានទេ លោក ហ៊ុន សែន ពុំអាចអនុញ្ញាតិឱ្យលោក សឺន សាន ចាកចេញពីអាកាសយានដ្ឋានមកកាន់ក្រុងភ្នំពេញបានជាដាច់ខាត ហើយលោក សឺន សាន ត្រូវរង់ចាំឡើងយន្តហោះត្រឡប់ទៅប្រទេសថៃវិញ។

ពេលនោះលោក សឺន សាន ពុំមានច្បាប់អនុញ្ញាតពីលោក ហ៊ុន សែន ទេ ពីព្រោះលោកពុំ



បានសុំដោយគិតថា ក្នុងនាមលោកជាប្រធានរណសិរ្សលោកត្រូវតែមានសិទ្ធិចូលមកកម្ពុជាវិញ។

ឃើញហេតុការណ៍ដូច្នេះ លោក ហ៊ុន សែន បានជំរាបទៅឯកឧត្តម សឺន សាន ថា សូមឯកឧត្តមជ្រាបថា សូម្បីសម្តេចនរោត្តម សីហនុ ក្នុងតំណែងធំជាប្រធានគណកម្មាធិការជាន់ខ្ពស់នៃឧត្តមក្រុមប្រឹក្សាជាតិ ក៏ព្រះអង្គបានសុំច្បាប់អនុញ្ញាតពី ហ៊ុន សែន ដែរ មុននឹងព្រះអង្គយាងចូលមក ចុះចំណែកឯកឧត្តម ហេតុអ្វីមិនសុំច្បាប់អនុញ្ញាតិពីខ្ញុំដែលជានាយករដ្ឋមន្ត្រីត្រួតត្រាកម្ពុជាផង ?

ដូច្នោះលោក សឺន សាន លោកជាមនុស្សប្រកបដោយគុណធម៌មានវីរភាពចំពោះប្រទេសនិងប្រជាជាតិលោកបានគោរពទៅតាមបញ្ញាតិរបស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ទាំងអស់ដើម្បីឱ្យបានចូលមកក្នុងប្រទេសកម្ពុជាវិញ ។ រួចហើយអនុវត្តតាមគោលការណ៍ដែលមានចែងនៅក្នុងសន្ធិសញ្ញាអន្តរជាតិ នាទីក្រុងប៉ារីសនោះទាំងស្រុង ។

ក្រោយពីថ្ងៃ២៣ ខែតុលា ឆ្នាំ១៩៩១នេះ សន្ធិសញ្ញាបានចែងអំពីការត្រូវបើកកិច្ចប្រជុំការងារ រវាងមេដឹកនាំភាគីនិមួយៗនៅទីក្រុងភ្នំពេញដើម្បីចរចារពិភាក្សាគ្នារៀបចំការបង្រួបបង្រួមគ្នាក្នុងគោលគំនិតបំភ្លេចចោលនូវនិន្នាការនយោ-បាយខុសគ្នាពីមុនជៀសវាងការបាក់បែកគ្នាតទៅទៀត ។ ជាពិសេសដើម្បីរៀបចំការបោះឆ្នោតសកលក្នុងពេលដ៏ខ្លីខាងមុខ ។

នៅក្នុងភាគីទាំងនេះមានភាគីខ្មែរក្រហមកម្ពុជាប្រជាធិបតេយ្យដែលមាន ខៀវ សំផន ជាប្រធាន និង សុន សេន ជាសហការីត្រូវចូលមកកាន់ទីក្រុងភ្នំពេញ ដើម្បីរួមប្រជុំដែរ ។

ប៉ុន្តែនៅពេលដែល ខៀវ សំផន និង សុន សេន បានចូលទៅដល់សណ្ឋាគារសម្រាប់ស្នាក់នៅនោះ ក៏កើតមានកំហឹងប្រជាពលរដ្ឋខ្មែរនាំគ្នាធ្វើមហាបាតុកម្មយ៉ាងធំប្រឆាំងវត្តមាន ខៀវ សំផន និង សុន សេន នេះ ។

កងនគរបាលការពារសន្តិសុខជាច្រើនបានចេញទៅធ្វើអន្តរាគមន៍រារាំងក្រុមបាតុករជាច្រើនដែលព្យាយាមទំលាយរបាំងការពារនៃនគរបាលក្នុងបំណងទៅវាយដេញឱ្យចេញត្រឡប់ទៅវិញមិនព្រមទទួលស្គាល់ក្រុមខ្មែរក្រហមនេះទេ ។ ដូច្នេះក្រោយពីក្រុមបាតុករមួយចំនួនបានទំលាយរបាំងការពារនេះបានហើយ ក៏បានចូលទៅដល់បន្ទប់សណ្ឋាគារ រួចហើយវាយ ខៀវ សំផន បែកក្បាលហូរឈាមសស្រាក់ ។ បន្ទាប់មកកងនគរបាលបានចូលទៅធ្វើការការពារយ៉ាងខ្លាំងក្លា ព្រមទាំងយកមួកដែកទៅប្រគល់ឱ្យ ខៀវ សំផន និង សុន សេន ពាក់ការពារក្បាលខ្លាចក្រែងបាតុករចូលទៅវាយបន្តទៀត ។

នៅក្នុងហេតុការណ៍នេះកើតឡើង លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន លោកបានចេញមុខដោយផ្ទាល់ ដើម្បីបញ្ជាឱ្យក្រុមមហាបាតុករបញ្ឈប់ និងដកថយរំសាយទៅវិញ ជៀសវាងកុំឱ្យមានបង្កើតហេតុការណ៍អ្វីធ្ងន់ធ្ងរទៅលើរូបឯកឧត្តម ខៀវ សំផន និង សុន សេន នេះ ។

បន្ទាប់មកលោក ហ៊ុន សែន សម្រេចឱ្យឯកឧត្តម ខៀវ សំផន និង សុន សេន ចាកចេញពីទីក្រុងភ្នំពេញទៅវិញជាបន្ទាន់ដែរ ។

នៅក្នុងការធានាសន្តិសុខដល់មេខ្មែរក្រហមទាំងពីររូបលោក ហ៊ុន សែន បានបញ្ជាឱ្យយករថពាសដែកចំនួន២គ្រឿងទៅដឹកនាំឯកឧត្តម ខៀវ សំផន និង សុន សេន ចេញពីសណ្ឋាគារដែលកំពុងតែចោមរោមយ៉ាងកកកុញដោយហ្វូងមហាបាតុករ ដើម្បីឱ្យបានត្រឡប់ទៅកាន់ប្រទេសថៃវិញ ។ **តទៅលេខក្រោយ**






តមកទំព័រទី ៩ ថ្ងៃសម្ពោធអណត្តិទី២ នៃប្រធានាធិបតីមានខ្មែរ...

លោក រដ្ឋា និយាយថា "នៅ ពេលខ្ញុំកំពុងល្បាត នៅលើមហាវិថីផែនស៊ីវេនៀ គ្រួសារខ្ញុំក៏កំពុង ចូលរួមពិធីសច្ចាប្រណិធានប្រធានាធិបតី ឯកូន ស្រីខ្ញុំកំពុងបំរើស្ម័គ្រចិត្តក្រុមក្មេង៧៥០០០នាក់ នារាត្រីសមោសរៀបចំដោយភរិយាប្រធានាធិបតី



∗ Michell Obama

I was one of the 15,000 selected , and one 1,800 team catains foe the 57th Presidential Inaugural. I am proud to say that I am the only Khmer person there. Captains Team leaders who pass the secret service background check were issue a photo ID to be worn with the Presidential Inauguration badge.

All volunteers were divided into various tasks and I was assigned to be the captain of outside control access with the secret service screening people who attend the inauguration parade in zone 5 including 13th ,14th and 15th Streets. There were 8 zones and the white House zone. My team and I managed the entrance on 14th Street on the north side of Pennsylvania Ave. Our day began at 5am to go over our assignment and by 5:30am we were at our station working alongside with secret service and other law enforcements. Our day ended when all president motorcade and parade participants reached the White House, which is around 6:00pm.

While working on the parade route along Pennsylvania, my family atteded the Swearing In ceremony of the President Obama´s second term in office at the US Capital in the morning.

My sixteen year old daughter was also volunteering at the Kid´s Inaugural Ball on Saturday, January 19,2013 in the Walter E. Washington Convention Center where the First Lady Michelle Obama Introduced Katy Perry who were among many star performers entertaining First Lady and her daughters along with about 5,000 attendees mostly children of the servicemen and servicewomen.

∗ Ratha Yem


# ផ្ទះជួល

**Philadelphia:** ផ្ទះមានបន្ទប់ដេក ២ សំរាប់ជួល តម្លៃ $600/១ខែ នៅតំបន់ Cottman/Castor (68xx Lynord) -តំបន់ដែលសម្បូរនីរថយន្ត ក្រុង និងហាងលក់ទំនិញ -អាចមកនៅបានភ្លាម

សូមទូរស័ព្ទទៅ : **215-514-2448**

# លក់ផ្ទះ DUPLEX នៅ LOGAN

**ហ្វីឡាដែលហ្វៀខាង ជើង:** លក់ផ្ទះមាន 2 appartments សម្រាប់គ្រួសារ ២-១ Unit មាន បីបន្ទប់ដេក មានបន្ទប់ទទួល ភ្ញៀវ បន្ទប់ទឹកចង្ក្រានបាយ ។ ស្ថិតនៅលើផ្លូវ Ruscom ក្បែរ ផ្លូវធំ Broad Street ដែល សម្បូរណ៏រថយន្តក្រុង និងមេត្រូ -អាចជួល បាន $1,400/ខែ ។ ម្ចាស់ផ្ទះប្រញាប់ទៅរស់នៅរដ្ឋ ផ្សេង ។ សូមទាក់ទងតាម ទូរស័ព្ទ Zina



**(267) 421-4340**




# ជោគជតារាសីទាំង 12 ប្រចាំឆ្នាំហាង



ជោគជតាប្រចាំសប្តាហ៍

**ឆ្នាំជូត**

រាល់កិច្ចការសព្វបែបយ៉ាងលោកអ្នកអាចជួបនឹង បញ្ហាខ្លះៗនាគ្រាដំបូង ប៉ុន្តែក្រោយមកមិនមាន អ្វីជាឧបសគ្គរារាំងទៀតឡើយ ។ ចំពោះអ្នកប្រកប មុខរបររកស៊ីជួញដូរវិញ មានការទិញចូលលក់ចេញគ្រាន់ បើ អាចរកផលកម្រៃត្រឡប់មកផ្ទះវិញយ៉ាងត្រជាក់ចិត្ត ។ រីឯ បញ្ហាស្នេហាមានភាពផ្អែមល្ហែម និងស្រស់ស្រាយប្រៀប ដូចត្រីក្នុងទឹកនារដូវខែវស្សាដូច្នេះដែរ ៕

**ឆ្នាំថោះ**

រាល់កិច្ចការដែលលោកអ្នកប៉ងប្រាថ្នាជាយូរមក ហើយនោះក្នុងរយៈពេលនេះ គឺបានសមដូចបំណង ហើយគ្មានអ្វីមករារាំងនោះទេ ហើយរាល់ការ ប៉ងយាយីពីមនុស្សដែលមានបំណងមិនល្អមកលើលោកអ្នក នោះក៏មិនបានសម្រេចដែរ ។ បើជាអ្នកប្រកបមុខរបរ រកស៊ីវិញអាចពង្រីកអាជីវកម្មឱ្យធំបន្ថែមទៀតបាន ។ ឯបញ្ហា ស្នេហា គូស្វាមីភរិយាមានភាពសុខដុមរមនាគ្មានផលរមាស់ អ្វីឡើយ ៕

**ឆ្នាំមមី**

លោកអ្នកគួរប្រុងប្រយ័ត្នចំពោះការនិយាយស្តី បន្តិច ពីព្រោះអាចនឹងមានគូសត្រូវចាំចាប់ទោស កំហុសមួលបង្កាច់បង្ខូចកេរ្តិ៍ឈ្មោះរបស់លោកអ្នកឱ្យប្រែក្លាយ ទៅជាស្មុយអសោចិ៍ ។ សម្រាប់អ្នកប្រកបមុខរបររកស៊ីជួញ ដូរវិញមានក្រុមមនុស្សតាមឈ្នានីសច្រើន ដូចច្នេះត្រូវប្រយ័ត្ន បន្តិចចៀសវាងការបរាជ័យ ។ រីឯបញ្ហាស្នេហាមានភាព ចម្រូងចម្រាសដាក់គ្នាបន្តិចបន្តួច ៕

**ឆ្នាំរកា**

រាល់ការបំពេញការងារទាំងឡាយលោកអ្នកមិន មានបញ្ហាអ្វីចោទនោះទេ ប៉ុន្តែក្នុងនោះសូម ប្រយ័ត្នកុំយកអាសាមនុស្សសម្បុរសឱ្យសោះ ព្រោះនាំឱ្យ កើតរឿងសៅហ្មងទៅថ្ងៃក្រោយ ។ សម្រាប់អ្នកប្រកប មុខរបររកស៊ីជួញដូរវិញ អាចសន្សំទុកបានខ្លះ ។ រីឯបញ្ហា ស្នេហាចូរកុំយកភាពមានះចង់ចាញ់ឈ្នះប្រយ័ត្នកើតមាន ជម្លោះវិវាទឈានដល់ការប្រេះស្រាំ ៕

**ឆ្នាំឆ្លូវ**

លោកអ្នកនឹងទទួលបាននូវលាភសក្ការៈពីភាគ ហ៊ុនរកស៊ី និងមិត្តរួមការងារយ៉ាងច្រើនគួរឱ្យ ពេញចិត្ត ។ លើសពីនេះទៅទៀតគម្រោងការដែលបាន ត្រៀមទុកនឹងបានសម្រេចដូចបំណងទៀតផង ។ បើជា អ្នកប្រកបមុខរបររកស៊ីវិញ គួរជួញដូរនៅទីជិតៗ ទើបសម ប្រកប ។ រីឯបញ្ហាស្នេហាគូស្នេហ៍ចេះស្តាប់ឱវាទគ្នា ៕

**ឆ្នាំរោង**

ក្នុងរយៈពេលនេះលោកអ្នកជួបនឹងបញ្ហាខាងផ្លូវ ចិត្តមិនសូវជាសប្បាយរីករាយប៉ុន្មាននោះទេ តែ ប្រសិនបើចង់ទទួលផលពីការងារនោះ ចូរធ្វើចិត្ត ឱ្យត្រជាក់ ទើបបានសម្រេចដូចបំណង ។ បើជាអ្នកប្រកប របររកស៊ីជួញដូរវិញ គឺមានការប្រទាំងប្រទើសជាមួយអ្នក មានមុខរបរដូចគ្នា ដូច្នេះគួរបើកចិត្តឱ្យទូលាយ ។ រីឯបញ្ហា ស្នេហាមានការកាំចិត្ត ព្រោះតែម្នាក់ៗចង់ចាញ់ឈ្នះគ្នានោះ ឯង ៕

**ឆ្នាំមមែ**

លោកអ្នកអាចនឹងមានអារម្មណ៍ច្របូកច្របល់ បន្តិចនៅក្នុងរយៈពេលនេះ ព្រោះកិច្ចការដែល ថា នឹងទទួលបានផលល្អនោះ វាអាចមានការប្រែប្រួល ដោយសារតែមានការរំខានពីអ្នកដទៃ ។ បើចំពោះអ្នក ប្រកបមុខរបររកស៊ីជួញដូរវិញ អាចរកផលកម្រៃគ្រាន់ បើគួរជាទីគាប់ប្រសើរជាងមុន ។ រីឯបញ្ហាស្នេហាពុំមាន ផលរមាស់អ្វីនោះឡើយ ៕

**ឆ្នាំច**

រាល់ការស្មុគស្មាញដែលធ្លាប់កើតមានលើលោក អ្នកក្នុងពេលនេះ នឹងត្រូវអហោសិកម្មទាំងអស់ ហើយទ្រព្យដែលរបូតចេញពីដៃទៅនឹងវិលត្រឡប់ មកវិញយ៉ាងគ្រប់គ្រាន់ ។ ចំពោះអ្នកប្រកបមុខរបររកស៊ី ជួញដូរវិញ ត្រូវគិតគូរឱ្យបានច្បាស់លាស់មុននឹងដាក់ទុនថ្មី ទើបមិនខាតបង់រាល់ការចំណាយទាំងនោះ ។ រីឯបញ្ហាស្នេហា ត្រូវចេះពូនជ្រោយចំណងស្នេហាដោយមានភាពផ្អែមល្ហែម ទើបជាការប្រសើរ ៕

**ឆ្នាំខាល**

អាចពោលបានថា លោកអ្នកមានសេចក្តីសុខ ក្នុងជីវិត និងការងារ ព្រោះវិបត្តិ និងភាពស្មុគ ស្មាញដែលមានកន្លងមកក៏បានធូរស្រាលឡើងវិញមួយកម្រិត ផងដែរ ។ បើជាអ្នកប្រកបមុខរបររកស៊ីវិញ ទោះបីជាចេញ ទៅជួញដូរនៅទីណាក្តីគួរចៀសវាងការដាក់ទុនថ្មី ព្រោះអាច នាំឱ្យខាតបង់ ។ រីឯបញ្ហាស្នេហាគូស្នេហ៍ច្រើនប្រចណ្ឌខុស រឿង ៕

**ឆ្នាំម្សាញ់**

លោកអ្នកមានភ័ព្វសំណាងល្អក្នុងការងារទទួល រឿងឡើងតួនាទី ឬប្រាក់បៀវត្សរ៍បន្ថែម ។ ជាង នេះទៀតនោះ ប្រសិនបើចង់ពឹងពាក់អ្នកមានយសស័ក្តិខ្ពង់ ខ្ពស់ក្នុងរឿងអ្វីមួយនឹងបានដូចបំណងផងដែរ ។ បើជាអ្នក ប្រកបមុខរបររកស៊ីវិញអាចរកប្រាក់ចំណូលចិញ្ចឹមគ្រួសារ បានដោយស្រួលទេ មិនមានអ្វីមករាំងស្ទះឡើយ ។ រីឯបញ្ហា ស្នេហាគូស្នេហ៍រមែងចេះអត់ឱនឱ្យគ្នា ៕

**ឆ្នាំវក**

នៅក្នុងរយៈពេលនេះ លោកអ្នកទទួលលាភសក្ការៈ ពីសាច់ញាតិបងប្អូនដែលជិតស្និទ្ធ ។ ក្រៅពីនោះ ក៏នៅទទួលបានដំណឹងល្អដែលមានប្រយោជន៍ ដល់ជាតិនិងការងាររបស់លោកអ្នកតទៅអនាគតទៀតផង ។ បើជាអ្នកប្រកបមុខរបររកស៊ីវិញផលកម្រៃទទួលបានកាក់ កបគ្រាន់បើ តែហាមកុំជួញដូរផ្លូវឆ្ងាញប្រយ័ត្នមានបញ្ហា ដល់ខ្លួន ។ រីឯបញ្ហាស្នេហាគូស្នេហ៍អាចមានការរកាំរកូសគ្នា ខ្លះ ប៉ុន្តែមិនធ្ងន់ធ្ងរនោះទេ ៕

**ឆ្នាំកុរ**

រាល់ការបំពេញការងាររបស់លោកអ្នកក្នុងរយៈ ពេលនេះ សុទ្ធតែផ្តល់នូវអត្ថប្រយោជន៍គួរឱ្យជា ទីពេញចិត្តទាំងអស់គ្មានអ្វីមករាំងស្ទះឡើយ ហើយជាងនេះទៀត នោះគម្រោងការដែលបានត្រៀមទុក ជាយូរមក ហើយក៏នឹងបានសម្រេចផងដែរ ។ បើជាអាជីវករ រកស៊ីវិញ មានការរីកចម្រើនលូតលាស់ទៅមុខជាលំដាប់ ។ រីឯបញ្ហាគូស្នេហ៍ច្រើនយល់ចិត្តគ្នា និងនឹករលឹកគ្នាបើនៅ ឆ្ងាយ ៕



មានមធ្យោបាយប្រសើរមួយ ។
អ្នកមិនគួរចាំបាច់ប្រឹងហួសហេតុពេកដើម្បីមានសុខភាពល្អទេ ។
នោះគឺជាមូលហេតុដែលផែនការ CHIP និង
Medicaid របស់យើងផ្តល់ជូន:
• សមាជិកភាព Y និង
Fitness Center
• Weight Watchers®
តម្លៃរហូតដល់ត្រឹមតែ $1,100 ក្នុងមួយឆ្នាំ!
HEALTH PARTNERS
1-800-553-0784
www.healthpart.com
chip
Pennsylvania's Children's
Health Insurance Program
www.chipcoverspakids.com
KidzPARTNERS
HEALTH PARTNERS
1-888-888-1211
www.kidzpartners.com




ផ្សារអាតាឡង់ទិក
Atlantic Market
135 main St, Danbury, CT 06810
203-830-3068
ATLANTIC MARKET
830-3068
FRESH FISH & PRODUCE
ASIAN GROCERIES
FRESH FISH IN TOWN
ផ្សារនេះមានម្ចាស់ឈ្មោះ **ដាន់ ស៊ីន** បើកលក់ដូរតាំងពី១០ឆ្នាំមកហើយ ជាពិសេសយើងជាអ្នកលក់ត្រីស្រស់ៗនៅក្នុងក្រុង ។ បន្ថែមពីលើលក់ត្រីស្រស់ យើងមានលក់បន្លែសម្រាប់ម្ហូបអាស៊ី ។
**យើងទទួលយក :** American Express -លុយសុទ្ធ -Debit card -Master Card -Visa
**បើកទ្វារ :** ថ្ងៃច័ន្ទ ម៉ោង ៩:៣០ព្រឹក ដល់៧ល្ងាច/ ថ្ងៃអង្គារ៍ ដល់ថ្ងៃសៅរ៍ ៩:៣០ដល់៨ល្ងាច/ ថ្ងៃអាទិត្យ ៩:៣០-៧:០០
ATLANTIC MARKET
ទីធ្លាចតរថយន្តឥតគិតថ្លៃ

## តមកទំព័រទី ១៧ រជ្ជកាលបន្ទាប់ពីសីហនុ

ព្រមទទួលស្គាល់តាមផ្លូវច្បាប់នូវឯករាជ្យរបស់កម្ពុជា ។ សន្ធិសញ្ញាឆ្នាំ១៩៤៩នេះលុបចោលនូវសន្ធិសញ្ញាអាណាព្យាបាលឆ្នាំ១៨៦៣ និង១៨៨៤ ។

ពីឆ្នាំ១៩៥២ ដល់១៩៥៣ ព្រះរាជាណាចក្រកម្ពុជាថ្វាយព្រះកិត្តិនាមថា "**ព្រះមហាវិរបុរសជាតិព្រះបិតាឯករាជ្យជាតិ**" ។

### ជីវភាពគ្រួសារ

ជាតំណព្រះរាជវង្សានុវង្សក្សត្រខ្មែរជាក្សត្រពហុពន្ធភាព (POLYGAMIE) ។ ព្រះនរោត្តម សីហនុ ក៏បានប្រតិបត្តិតាមទម្លាប់នេះ ។ តាំងពីឆ្នាំ១៩៤១ រហូតដល់ទសវត្សឆ្នាំ៦០ ព្រះសីហនុ មានមហេសី៦ និងបុត្រា-បុត្រី១៤អង្គ មហេសីខ្លះជាក្សត្រីជាប់រាជវង្ស ខ្លះទៀតជារាស្ត្រគេហៅថា "អ្នកម្នាង" ។

| **មហេសី** | **បុត្រា_បុត្រី** |
| --- | --- |
| **១-នរោត្តម នរល័ក្ខ** | **គ្មាន** |
| **២-ស៊ីសុវត្ថិ ពង្សមុនី** | **យុវនាថ, រវិវង្ស, ចក្រពង្ស, សុរិយាវង្សី, គន្ធបុប្ផា** |
| **៣-ស៊ី សុវត្ថិ មុនីកេសនា** | **ណារាធិប៉ូ(១៩៤៦-១៩៧៥)** |
| **៤-ផាត កាញ៉ុល** | **បុប្ផាទេវី, រណឫទ្ធិ** |
| **៥-មុនីវណ្ណា ផានិវង្ស** | **សុជាតា (១៩៦៣ -១៩៣៦) , អរុណរស្មី,** |
| **៦-ប៉ូល ម៉ូនិក អ៊ីហ្ស៊ី** | **សីហមុនី, នរិន្ទ្រពង្ស (១៩៥៤-២០០៣)** |

នៅពេលគ្រងរាជ្យលើកទី២ អ្នកម្នាង ម៉ូនិក បានឡើងឋានៈ ជាព្រះអគ្គមហេសី "មុនីនាថ" ។ ព្រះរាជបុត្រា សីហមុនី ពេលឡើងគ្រងរាជ្យមានឈ្មោះថា "**ព្រះបាទសម្តេច ព្រះបរមនាថនរោត្តម សីហមុនី**" ជាឈ្មោះផ្គុំគ្នារវាង "សីហនុ"+ "មុនី" ។

### នយោបាយ

ប្រទេសកម្ពុជាបានត្រូវដឹកនាំជាងពាក់កណ្តាលសតវត្សដោយសម្តេចនរោត្តមសីហនុនៅសតវត្សទី២០នេះ ។ ព្រះអង្គជាអ្នកនយោបាយ, ជាកវីនិពន្ធបទចម្រៀង,អ្នកប្រលោមលោក,អ្នកដើរតួកុន និងអ្នកកាសែត ។ សកម្មភាពនយោបាយរបស់ព្រះអង្គអាចសង្ខេបដូចតទៅនេះ :

-ពីថ្ងៃទី២៤ មេសា ១៩៤១ ដល់ថ្ងៃទី ៣ មិនា ១៩៥៥ ព្រះមហាក្សត្រកម្ពុជាឡើងគ្រងរាជសម្បត្តិពេលព្រះស៊ីសុវត្ថិមុនីវង្ស (ជីតា) សុគត និងបានថ្វាយរាជ្យសម្បត្តិទៅព្រះនរោត្តមសុរាម្រិត (បិតា) ។

-ពីខែមេសា ១៩៦០ ដល់ថ្ងៃទី១៨ មិនា ១៩៧០ ជាប្រមុខរដ្ឋមានងារជា "**សម្តេច**" ។ តំណែងប្រមុខរដ្ឋនេះបានត្រូវសភាទាំងពីរបោះឆ្នោតទំលាក់ដោយសារព្រះអង្គអនុញ្ញាតឱ្យទ័ពយួនកុម្មុយនីស្តប្រើប្រាស់ទឹកដីខ្មែរធ្វើសង្គ្រាមទៅប្រទេសយួនខាងត្បូង ។ ធ្លាក់ពីតំណែងសម្តេចសីហនុបានបង្កើតចលនាតស៊ូប៉ិន និងបង្កើតរាជរដ្ឋាភិបាលរំដោះជាតិ (GRUNK) ជាមួយខ្មែរក្រហមនៅប៉េកាំងប្រឆាំងទៅរបបសាធារណរដ្ឋខ្មែរលន់នល់ ។

-នៅខែមេសា ១៩៧៥ នៅ ពេលខ្មែរក្រហមឈ្នះសង្គ្រាម និងកាន់អំណាចសម្តេចសីហនុបានវិលត្រឡប់ចូលភ្នំពេញ មានតួនាទីជា "**ប្រមុខរដ្ឋ**" រហូតដល់ថ្ងៃទី៤ មេសា ១៩៧៦ ទើបប្តូរទៅឱ្យលោក ខៀវ សំផន កាន់ តំណែងនេះតទៅទៀត ។

-នៅឆ្នាំ១៩៧៩នៅពេលខ្មែរក្រហម ប៉ុល ពត ធ្លាក់ពីតំណែងដោយសារទ័ពយួនសម្តេច សីហនុបានភៀសព្រះអង្គទៅប៉េកាំង បន្ទាប់មកទៅព្យុងយ៉ាងកូរ៉េខាងជើងដែលនៅទីក្រុងព្រះអង្គបានបង្កើត "សហព័ន្ធខ្មែរជាតិនិយម" ប្រឆាំងទៅទ័ពយួន ។

-ពីឆ្នាំ១៩៨៦ដល់១៩៩៨ក្នុងការតស៊ូប្រយុទ្ធប្រឆាំងទៅទ័ពយួន និងខ្មែរកាន់អំណាចដោយសារការគាំទ្ររបស់យួនព្រះអង្គជាប្រធានរដ្ឋាភិបាលចំរុះ៣ភាគី : សីហនុ, សឺន សាន,កម្ពុជាប្រជាធិបតេយ្យ, (ប៉ុលពត) ។ ព្រះអង្គស្ថិតនៅក្រុងប៉េកាំង ។

-ពីថ្ងៃទី ២០ វិច្ឆិកា ១៩៩៣ សម្តេច សីហនុបានវិលត្រឡប់ចូលភ្នំពេញ នៅថ្ងៃទី១៤ វិច្ឆិកា១៩៩១ ។

-ពីថ្ងៃទី ២៤ កញ្ញា ១៩៩៣ ហួតដល់ថ្ងៃទី៧ តុលា ២០០៤ ព្រះអង្គឡើងគ្រងរាជ្យជាថ្មី នៅថ្ងៃទី២៤ កញ្ញា១៩៩៣ រហូតដល់ថ្ងៃទី២០ តុលា ២០០៤ ទើបដាក់រាជ្យ ។ ក្រុមប្រឹក្សារាជសម្បត្តិបានជ្រើសរើសរាជបុត្រានរោត្តម សីហមុនីជាស្តេចឡើងគ្រងរាជ្យបន្ត ។

តាំងពីឆ្នាំនោះមកព្រះអង្គ សីហនុ គង់ នៅតែក្រុងប៉េកាំងប្រទេសចិនសម្រាប់ព្យាបាលរោគជម្ងឺមហារីកតែព្រះអង្គយាងមកស្រុកខ្មែរម្តងម្កាលដែរ ។ សម្តេចនរោត្តមសីហនុបានសោយទិវង្គត នៅថ្ងៃច័ន្ទ ទី១៥ តុលា ឆ្នាំ២០១២ នៅក្រុងប៉េកាំងសាធារណរដ្ឋប្រជាមានិតចិនក្នុងជន្មាយុ៩០ឆ្នាំ ៕






# Photos Album

Thank You to Campaign Volunteers from the Congresswoman Niki Tsongas for her 2nd term victory relection representing D-MA 3rd District. Sunday Luncheon on February 10th, 2013 (the day after Winter Storm Nemo (Blizzard of 2013) -- at La Boniche Restaurant, Downtown, Lowell, Massachusetts.




# មជ្ឈមណ្ឌលសុខភាពពេលថ្ងៃសម្រាប់ជនពេញវ័យ

## HOME AWAY FROM HOME ADULT DAY HEALTH CENTER



នៅពេលលោកអ្នក ឬមនុស្សសំណព្វចិត្តរបស់លោកអ្នកត្រូវការគេជួយនៅពេលថ្ងៃ មជ្ឈមណ្ឌលយើងមានសេវាកម្មអ្នកថែទាំមានវិជ្ជាជីវៈ អាចនិយាយភាសាអង់គ្លេស ខ្មែរ ចិន និងស្ប៉ាញ៉ូលបាន ។



**យើងអាចផ្ដល់ជូនសេវា ដូចតទៅ :**

- ថែទាំ សំអាត ធ្វើការសង្គមកិច្ចជូន និងព្យាបាលរាងកាយ
- ដឹកជញ្ជូនទៅមកពីផ្ទះទៅមជ្ឈមណ្ឌល និងទៅជួបពេទ្យ
- នាំចេញទៅភោជនីយដ្ឋានខ្មែរ -ទៅទិញឥវ៉ាន់ផ្សេងៗ ឬទៅមើលកន្លែងវប្បធម៌នានា
- មានការស្ដាប់ និងលេងភ្លេង មើលកុន កំសាន្តល្បែង ថ្នាក់សិក្សា និងការហាត់ប្រាណរាល់ថ្ងៃ
- បើកទ្វារពីថ្ងៃច័ន្ទដល់ថ្ងៃសៅរ៍ ពីម៉ោង៧ព្រឹកដល់៤ល្ងាច ឬក៏ប្ដូរម៉ោងក៏បានតាមតម្រូវការ

**យើងទទួល អ៊ិនស្វរិន ស្ទើរគ្រប់មុខ**

- Mass Health • Evercare • Navicare • Senior Whole Health • Elder Services of the Merrimack Valley

## Our Services and Programs

- Nursing, social work and physical therapy
- Transportations
- Breakfast, lunch and snacks
- Outings to Cambodian restaurants, shopping, and cultural events
- Entertainments, spiritual classes and exercise daily

សូមទាក់ទងទៅ ខារិន បន គ្ការីហ្គាន់ (Karen Bond Garrigan) 978-453 Home (978-453-4663) ដើម្បីនាំទៅមើលមជ្ឈមណ្ឌល
Conveniently located at 150 Industrial Avenue East in Lowell, right off the Lowell Connector
Open Monday-Friday 7-4 and Saturday 7:30-2:00 PM
www.homeawayfromhomeADHC.com

# Collegiate Charter School of Lowell

## សាលារៀនអន្តរជាតិ និងបើកថ្មី បង្រៀន_សម្រាប់ទៅមហាវិទ្យាល័ ផ្ដើមបើក នៅខែកញ្ញា ២០១៣ នេះហើយ ហើយផ្ដល់សេវាឲ្យសិស្សតាំងពីថ្នាក់មត្តេយ្យដល់ថ្នាក់ទី៥

## អនុវិទ្យាល័យ ឆាទ័រ នៃក្រុងឡូវែល

**ផ្ដើមចុះឈ្មោះ ហើយ !**



- កម្មវិធីត្រៀមទៅវិទ្យាល័យ
- មានឯកសណ្ឋានសិស្ស
- បង្រៀនចរិយាសម្បត្តិ
- សង្កត់លើគណិតវិទ្យា និង អង់គ្លេសខ្លាំង
- ពេលរៀនច្រើនក្នុង១ថ្ងៃ
- ក្រមចរិយាមានច្បាស់លាស់
- មានក្ដីសង្ឃឹមខ្ពស់
- សាស្ត្រាចារ្យមានសញ្ញាប័ត្រខ្ពស់
- ការចូលរួមរបស់ឪពុកម្ដាយ
- កម្មវិធីកំសាន្តក្រៅយ៉ាងសប្បាយ
- កម្មវិធីមុននឹងក្រោយម៉ោងរៀន
- កន្លែងថ្មីស្អាត និងសុវត្ថិភាព
- ពង្រីកដល់សាលាដែលមាន ថ្នាក់កំរិត១២
- សិក្សាឥតយកតម្លៃជាសាធារណៈ

1886

**ការិយាល័យចុះឈ្មោះ**

1857 Middlesex Street, Lowell, MA 01851
Phone: (978) 458-1399
E-mail: LCCS@sabis.net
www.LCCS.SABIS.net

*Member of the SABIS® School Network*